លឹម ផល្គុន និង សែន ពិសិដ្ឋ

# លំហាត់ និង ដំណោះស្រាយ

# គណិតវិទ្យា

## ត្រៀមប្រឡងសញ្ញាបត្រទុតិយភូមិ

## និង អាហារូបករណ៍

**Problems and Solutions**

# ស្នាដៃបោះពុម្ពផ្សាយ

***សៀវភៅគណិតវិទ្យា*** ៖

១_ដំណោះស្រាយលំហាត់គណិតវិទ្យា បោះពុម្ព ឆ្នាំ២០០០

( សម្រាប់ត្រៀមប្រឡងចូលសាកលវិទ្យាល័យ និង អាហារូបករណ៍ )

២_ពិភពស៊ីតចំនួនពិត ( សម្រាប់ថ្នាក់ទី១១ និង សិស្សពូកែគណិតវិទ្យា )

៣_ អនុគមន៍ត្រីកោណមាត្រ ( សម្រាប់ថ្នាក់ទី១១ និង សិស្សពូកែគណិតវិទ្យា )

៤_ ដំណោះស្រាយគំរូ ចំនួនកុំផ្លិច លីមីត ដេរីវេ ( សម្រាប់ថ្នាក់ទី១២)

៥_ សង្ខេបរូបមន្តគណិតវិទ្យា ( សម្រាប់ថ្នាក់ទី១១_១២ )

៦_ គំរូសិក្សាអនុគមន៍ ( សម្រាប់ថ្នាក់ទី១១_១២ )

៧_ កំនែលំហាត់គណិតវិទ្យាថ្នាក់ទី១០កម្មវិធីសិក្សាថ្មី ( ភាគ១ ឆ្នាំ២០០៨ )

៨_ **151** គណនាលីមីត ( សម្រាប់ថ្នាក់ទី១១_១២ )

៩_ **202** លំហាត់មានដំណោះស្រាយ ( សម្រាប់ថ្នាក់ទី១២ )

✍✍✍✍✍

អ្នកចូលរួមត្រួតពិនិត្យបច្ចេកទេស

លោក លឹម ឆុន

លោក សែន ពិសិដ្ឋ

លោកស្រី ទុយ រីណា

លោក ទិត្យ ម៉េង

លោក ព្រឹម សុនិត្យ

លោក ផល ប៊ុនឆាយ

អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិគ្គសិរ

ការីកុំព្យូទ័រ

កញ្ញា លី គុណ្ណាកា

អ្នកនិពន្ធ និង រៀបរៀង

លោក លឹម ផល្គុន និង លោក សែន ពិសិដ្ឋ

# អារម្ភកថា

សៀវភៅ **លំហាត់មានដំណោះស្រាយ** ដែលអ្នកសិក្សាកំពុងកាន់នៅក្នុងដៃនេះ ខ្ញុំបាទបានរៀបរៀងឡើងក្នុងគោលបំនងទុកជាឯកសារ សម្រាប់ជាជំនួយដល់អ្នកសិក្សាយកទៅសិក្សាស្រាវជ្រាវដោយខ្លួនឯង និង ម្យ៉ាងទៀតក្នុងគោលបំនងចូលរួមលើកស្ទួយវិស័យគណិតវិទ្យានៅប្រទេសកម្ពុជាយើងឲ្យកាន់តែរីកចម្រើនថែមទៀតដើម្បីបង្កើនធនធានមនុស្សឲ្យមានកាន់តែច្រើនដើម្បីជួយអភិវឌ្ឍន៍ប្រទេសជាតិរបស់យើង ។

នៅក្នុងសៀវនេះយើងខ្ញុំបានខិតខំស្រាវជ្រាវជ្រើសរើសយកលំហាត់យ៉ាងសម្រាំងបំផុតយកមកធ្វើដំណោះស្រាយយ៉ាងក្បោះក្បាយដែលអាចឲ្យលោកអ្នកងាយយល់ឆាប់ចងចាំអំពីសិល្បៈនៃការដោះស្រាយទាំងអស់នេះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កង្វះខាត និង កំហុសឆ្គងដោយអចេតនាប្រាកដជាមានទាំងបច្ចេកទេស និង អក្ខរាវិរុទ្ធ ។ អាស្រ័យហេតុនេះ យើងខ្ញុំជាអ្នករៀបរៀងរង់ចាំដោយរីករាយជានិច្ចនូវមតិរិះគន់បែបស្ថាបនាពីសំណាក់អ្នកសិក្សាក្នុងគ្រប់មជ្ឈដ្ឋានដើម្បីជួយកែលំអ សៀវភៅនេះឲ្យបានកាន់តែសុក្រិត្រភាពថែមទៀត ។

ជាទីបញ្ចប់នេះយើងខ្ញុំអ្នករៀបរៀងសូមគោរពជូនពរដល់អ្នកសិក្សាទាំងអស់ឲ្យមានសុខភាពមាំមួន និង ទទួលជ័យជំនះគ្រប់ភារកិច្ច ។

**បាត់ដំបងថ្ងៃទី១៧ កុម្ភះ ២០០៩**

**អ្នកនិពន្ធ លឹម ផល្គុន**

# លំហាត់ និង ដំណោះស្រាយ

១-គេឲ្យសមីការ $(E): z^2 + iaz + a + ib = 0$ ដែល $a , b \in IR$

ក-កំនត់ $a$ និង $b$ ដើម្បីឲ្យ $z_1 = -1 + i\sqrt{3}$ ជាឫសមួយរបស់សមីការ $(E)$ រួចគណនាឫសមួយទៀត $z_2$ ។

ខ-ចូរសរសេរ $z_1$ , $z_2$ និង $\frac{z_1}{z_2}$ ជាទម្រង់ត្រីកោណមាត្រ ។

គ-ទាញបញ្ជាក់តម្លៃប្រាកដនៃ $\cos\frac{5\pi}{12}$ និង $\sin\frac{5\pi}{12}$ ។

២-គេឲ្យអនុគមន៍ $f(x)$ កំនត់លើ $IR$ ដោយ ៖

$$f(x) = \ln(x^2 - x\sqrt{2} + 1) - \ln(x^2 + x\sqrt{2} + 1)$$

ក-ចូរគណនាតម្លៃ $f(-\sqrt{2})$ , $f(0)$ និង $f(\sqrt{2})$ ។

បង្ហាញថា $f(x)$ ជាអនុគមន៍សេស ។

ខ-គណនាដេរីវេ $f'(x)$ និង $f''(x)$ ។

៣-គេឲ្យចំនួនកុំផ្លិច $z = x + i.y$ ដែល $x$ និង $y$ ជាពីរចំនួនពិត ។

ចូរកំនត់តម្លៃ $x$ និង $y$ បើគេដឹងថា៖

$$(3 + 2i)z + (1 + 3i)\bar{z} = \frac{10}{2 - i}$$

( $\bar{z}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ $z$ ) ។

៤_គេអោយចំនួនកុំផ្លិច $z=\cos\frac{4\pi}{7}+i.\sin\frac{4\pi}{7}$ ។

ចូរសរសេរ $(1+z)^4$ជារាងត្រីកោណមាត្រ ។

៥_គេអោយចំនួនកុំផ្លិច : $z_1=\frac{\sqrt{6}-i.\sqrt{2}}{2}$ និង $z_2=1-i$

ក.ចូរសរសេរ $z_1$ ,$z_2$និង $Z=\frac{z_1}{z_2}$ ជារាងត្រីកោណមាត្រ។

ខ.ចូរសរសេរ $Z=\frac{z_1}{z_2}$ ជារាងពិជគណិត។

គ.ទាញអោយបានថា $\cos\frac{\pi}{12}=\frac{\sqrt{6}+\sqrt{2}}{4}$ និង $\sin\frac{\pi}{12}=\frac{\sqrt{6}-\sqrt{2}}{4}$ ។

៦_គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to0}\frac{e^x+2\sin x-1}{x}$ ខ. $\lim\limits_{n\to+\infty}\left(\frac{2n}{2n-1}\right)^{n+1}$

៧_ចូរគណនាលីមីត ៖

ក. $\lim\limits_{x\to0}\frac{e^{-x^2}-\cos x}{x^2}$ ខ. $\lim\limits_{x\to0}\frac{e^x-e^{-x}}{\sin x}$

៨_ចូរគណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{n\to+\infty}\left(1+\frac{1}{n}\right)^{n+5}$ ខ. $\lim\limits_{n\to+\infty}\left(\frac{n-1}{n+1}\right)^{n+2}$

៩_កំនត់ចំនួនពិត x និង y ដើម្បីអោយ $(x+1)+(3+2y).i=\frac{7+9i}{3+2i}$

១០_គេអោយ $f(z)=z^3-2(\sqrt{3}+i).z^2+4(1+i\sqrt{3}).z-8i$

ក.ចូរបង្ហាញថា $\forall z\in ℂ\ \ f(z)=(z-2i)(z^2-2\sqrt{3}z+4)$

ខ.ដោះស្រាយសមីការ $f(z)=0$ ក្នុងសំណុំកុំផ្លិច ។

១១_ចូរគណនាលីមីត :

ក. $\lim\limits_{x\to 0}\dfrac{1-\cos 2x+x\sin 2009x}{x^2}$

ខ. $\lim\limits_{x\to 3}\dfrac{x^3-3x^2+(a-1)x+3-3a}{x^2-4x+3}$

១២_គេអោយអនុគមន៍ $f(x)=x^3-6x^2+9x-3$

ក.បង្ហាញថាមានតំលៃ $x_0$ ដែល $1<x_0<2$ ហើយ $f(x_0)=0$ ។

ខ.គណនាដេរីវេ $f'(x)$ ហើយសិក្សាសញ្ញានៃ $f'(x)$ ។

សង់តារាងអថេរភាពនៃ $f(x)$ ។

១៣_គេមានអនុគមន៍ $f(x)=\sqrt{3x+1}$ កំនត់លើ $\left[-\dfrac{1}{3},+\infty\right]$

ក. ចំពោះគ្រប់ $x\in[1,5]$ ចូរបង្ហាញថា $\dfrac{3}{8}\le f'(x)\le \dfrac{3}{4}$ ។

ខ. ដោយប្រើវិសមភាពកំណើនមានកំនត់ទៅនឹងអនុគមន៍ $f$ ចំពោះគ្រប់

$x\in[1,5]$ ចូរបង្ហាញថា $\dfrac{3}{8}x+\dfrac{13}{8}\le\sqrt{3x+1}\le\dfrac{3}{4}x+\dfrac{5}{4}$

១៤_គេឱ្យអនុគមន៍ $f(x)=ax+2+b.\ln x$ កំនត់លើចន្លោះ $]0,+\infty[$

ចូរកំនត់ចំនួនពិត a និង b ដើម្បីឱ្យខ្សែកោង (c) តាងអនុគមន៍ $y=f(x)$

ប៉ះនឹងបន្ទាត់ $(T): y=2x-3$ ត្រង់ចំនុច $A(1,-2)$ ។

១៥_គេឱ្យអនុគមន៍ $f(x)=\begin{cases} \dfrac{\sin x+\cos x-\sqrt{2}}{(\frac{\pi}{4}-x)^2} & \text{បើ } x\neq\frac{\pi}{4} \\ -\dfrac{\sqrt{2}}{2} & \text{បើ } x=\frac{\pi}{4} \end{cases}$

ចូរសិក្សាភាពជាប់នៃអនុគមន៍ f ត្រង់ចំនុច $x_0=\frac{\pi}{4}$ ។

១៦_គេឱ្យអនុគមន៍ $f(x)=ax+b-\frac{\ln x}{x}$

ដែល $x>0$ ហើយ a និង b ជាចំនួនពិត។

ក-បង្ហាញថាចំពោះគ្រប់ចំនួនពិត a និង b ដែល $a\neq 0$ ខ្សែកោង $(C)$

តាងអនុគមន៍ $f(x)$ មានអាស៊ីមតូតទ្រេតមួយដែលគេនឹងបញ្ជាក់សមីការ ។

ខ-កំនត់ចំនួនពិត a និង b ដើម្បីឱ្យខ្សែកោង $(C)$ តាងអនុគមន៍ $f(x)$

ប៉ះទៅនឹងបន្ទាត់ $(T): y=x+4$ ត្រង់ចំនុច $A(1,5)$ ។

១៧_គេឱ្យអនុគមន៍ $f(x)=\frac{\sin(\pi x)}{1-x^3}$ កំនត់គ្រប់ $x\neq 1$ ។

តើគេអាចបន្លាយអនុគមន៍ f ឱ្យជាប់ត្រង់ចំនុច $x_0=1$ បានឬទេ ?

បើអាចកំនត់រកអនុគមន៍បន្លាយតាមភាពជាប់នៃអនុគមន៍ $f(x)$ ត្រង់ $x_0=1$

១៨_គេឱ្យអនុគមន៍ពីរ

$F(x)=(ax^3+bx^2+cx+d).e^x$ និង $f(x)=x^3.e^x$ កំនត់លើ IR ។

កំនត់ចំនួនពិត $a,b,c$ និង $d$ ដើម្បីឱ្យ$F(x)$ជាព្រីមីទីវនៃអនុគមន៍ $f(x)$

១៩_គេឱ្យអនុគមន៍ $f(x)=ax+b-e^x$ មានក្រាបតំនាង $(c)$ ។

កំនត់ចំនួនពិត $a$ និង $b$ ដើម្បីឱ្យខ្សែកោង $(c)$ ប៉ះនឹងបន្ទាត់$(d): y=x+3$

ត្រង់ចំនុច $A(0,3)$ ។

២០_គេឱ្យអនុគមន៍ $f(x)=ax+b-x.\ln x$ មានក្រាបតំនាង $(c)$ ។

កំនត់ចំនួនពិត $a$ និង $b$ ដើម្បីឱ្យខ្សែកោង $(c)$ ប៉ះនឹងបន្ទាត់

$(d): y=x+1$ ត្រង់ចំនុច $A(1,2)$ ។

២១_គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+mx+4}{x^2+1}$

ដែល $x$ ជាចំនួនពិត និង $m$ ជាប៉ារ៉ាម៉ែត្រ ។

ក. ចូរកំនត់តម្លៃ $m$ ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាត្រង់ចំនុច $x=2$ ។

ខ. ចូរកំនត់តម្លៃ $m$ ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាតែមួយគត់ ។

២២_គេមានអនុគមន៍ $f(x)=\dfrac{3x^2-7x+6}{(x-3)^2(x+1)}$

ក-សរសេរ $f(x)$ជាទំរង់ $\dfrac{A}{x+1}+\dfrac{B}{x-3}+\dfrac{C}{(x-3)^2}$

រួចគណនាតំលៃ $A,B$ និង $C$ ។

ខ-គណនា $\int_1^2 f(x).dx$ ដោយសរសេរចំលើយជាទំរង់ $a+\ln b$ ដែល $a$ និង$b$ ជាចំនួនសនិទាន។

២៣_គេឲ្យអនុគមន៍ $g(x)=\frac{2x^2-5x-1}{x^3-x}$ ដែល $x\neq 0$ , $x\neq \mp 1$ ។

ក.កំនត់ចំនួនពិត $A, B$ និង $C$ ដើម្បីឲ្យ $g(x)=\frac{A}{x}+\frac{B}{x-1}+\frac{C}{x+1}$

ខ.ចូរគណនា $I=\int g(x).dx$ ។

២៤_គេមានអនុគមន៍ $f(x)=\frac{2x^2+2x+1}{x^3+x^2}$ ដែល $x\neq 0$ និង $x\neq -1$

ក_កំនត់ចំនួនពិត $A, B, C$ ដើម្បីឲ្យ $f(x)=\frac{A}{x}+\frac{B}{x^2}+\frac{C}{x+1}$ ។

ខ_គណនាអាំងតេក្រាល $I=\int f(x).dx$ ។

២៥_គេមានអនុគមន៍ $f(x)=\frac{3x^2-7x+6}{(x-3)^2(x+1)}$

ដែល $x\neq -1$ និង $x\neq 3$ ។

ក_កំនត់បីចំនួនពិត $a, b, c$ ដើម្បីឲ្យ $f(x)=\frac{a}{x+1}+\frac{b}{x-3}+\frac{c}{(x-3)^2}$

ខ_គណនាអាំងតេក្រាល $I=\int_0^1 f(x).dx$ ។

២៦_គេឱ្យអនុគមន៍ $f(x)$ កំនត់ និង មានដេរីវេត្រង់ចំនុច $x=c$ ។

ចូរស្រាយបញ្ជាក់ថា $\lim_{h\to 0}\frac{f^2(c+h)-f^2(c-h)}{h}=4f'(c).f(c)$ ។

២៧_គេឱ្យអនុគមន៍ $f(x)=\frac{e^x}{ax+b}$ ដែល $a\neq 0, a, b\in IR$

ក-ចូរគណនាដេរីវេ $f'(x)$ និង $f''(x)$

ខ-កំនត់ចំនួនពិត a និង b ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអប្បបរមាស្មើ e ចំពោះ $x=1$ ។

២៨_គេឱ្យអនុគមន៍ f កំនត់លើ IR ដោយ $f(x)=\sin x$

ចូរបង្ហាញថាដេរីវេទី n នៃអនុគមន៍ f កំនត់ដោយ $f^{(n)}(x)=\sin(x+\frac{n\pi}{2})$

២៩_គេមានអនុគមន៍ $f(x)=\frac{4x^2-x+1}{x^3+1}$ ដែល $x\neq -1$ ។

ក-កំនត់បីចំនួនពិត a , b , c ដើម្បីឱ្យ $f(x)=\frac{a}{x+1}+\frac{bx+c}{x^2-x+1}$ ។

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$ ។

៣០_គេមានអនុគមន៍ $f(x)=\frac{5x^2-14x+13}{(x+1)(x-3)^2}$ ដែល $x\neq -1$ និង $x\neq 3$ ។

ក-កំនត់បីចំនួនពិត a , b , c ដើម្បីឱ្យ $f(x)=\frac{a}{x+1}+\frac{b}{x-3}+\frac{c}{(x-3)^2}$

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$ ។

៣១_គេឱ្យអនុគមន៍ $f(x)=\frac{1}{x(1+x^4)}$ ដែល x ជាចំនួនពិតខុសពីសូន្យ ។

ក-ចូរកំនត់បីចំនួនពិត A ,B និង C ដើម្បីឱ្យ $f(x)=\frac{A}{x}+\frac{Bx^3+C}{1+x^4}$

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$ ។

គ-ទាញរកអាំងតេក្រាល $J=\int \frac{4x^3\ln x.dx}{(1+x^4)^2}$

៣២_គេឱ្យអនុគមន៍ $f(x)=\frac{1}{e^{2x}+1}$ ដែល x ជាចំនួនពិត ។

ក-ចូរកំនត់បីចំនួនពិត A និង B ដើម្បីឱ្យ $f(x)=A+\frac{B.e^{2x}}{e^{2x}+1}$

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$ ។

គ-ទាញរកអាំងតេក្រាល $J=\int \frac{2xe^{2x}.dx}{(e^{2x}+1)^2}$

៣៣_គេឱ្យអាំងតេក្រាល $I=\int e^x\cos^2 x.dx$ និង $J=\int e^x\sin^2 x.dx$

ក-ចូរគណនា $I+J$ និង $I-J$

ខ-ទាញរក I និង J

៣៤_គេឱ្យអាំងតេក្រាល :

$I=\int \frac{1+\cos x}{2+\sin x+\cos x}.dx$ និង $J=\int \frac{1+\sin x}{2+\sin x+\cos x}.dx$

ក-គណនា $I+J$ និង $I-J$

ខ-ទាញរក I និង J

៣៥_ គេឲ្យអាំងតេក្រាល $I_0 = \int_0^1 \frac{dt}{1+t+t^2}$

និង $I_n = \int_0^1 \frac{t^n}{1+t+t^2}.dt$ , ( $n \in IN$ )

ក_ចូរគណនាតម្លៃនៃ $I_0$ រួច ស្រាយថា $(I_n)$ជាស្វ៊ីតចុះ។

ខ_ស្រាយបញ្ជាក់ថា $I_n + I_{n+1} + I_{n+2} = \frac{1}{n+1}$ ។

គ_ទាញឲ្យបានថា $\frac{1}{3(n+1)} \le I_n \le \frac{1}{3(n-1)}$ , $\forall n \ge 2$ ។

ទាញរកលីមីត $\lim\limits_{n\to+\infty}(nI_n)$។

៣៦_គេឱ្យអាំងតេក្រាល $I = \int x\cos^2 x.dx$ និង $J = \int x\sin^2 x.dx$

ក-ចូរគណនា $I + J$ និង $I - J$

ខ-ទាញរក $I$ និង $J$

៣៧_គេមានអនុគមន៍ $f(x) = \frac{6x^2 - 22x + 18}{(x-1)(x-2)(x-3)}$ ដែល$x \ne \{1, 2, 3\}$ ។

ក-កំនត់បីចំនួនពិត $a, b, c$ ដើម្បីឱ្យ $f(x) = \frac{a}{x-1} + \frac{b}{x-2} + \frac{c}{x-3}$ ។

ខ-គណនាអាំងតេក្រាល $I = \int f(x).dx$ ។

៣៨_គេមានអាំងតេក្រាល $I=\int_{0}^{\frac{\pi}{4}}\cos^2 x.dx$ និង $J=\int_{0}^{\frac{\pi}{4}}\sin^2 x.dx$

ក-ចូរគណនា $I+J$ និង $I-J$ ។

ខ-ទាញរកតម្លៃនៃ I និង J ។

៣៩_គេមានអនុគមន៍ $f(x)=\frac{2x+1}{x(x+1)}$ ដែល $x\neq -1$ និង $x\neq 0$ ។

ក-កំនត់បីចំនួនពិត A និង B ដើម្បីឲ្យ $f(x)=\frac{A}{x}+\frac{B}{x+1}$ ។

ខ-គណនាអាំងតេក្រាល $I=\int_{1}^{3}f(x).dx$ ។

៤០_គេមានអាំងតេក្រាល $I=\int_{\frac{\pi}{4}}^{\frac{\pi}{2}}\frac{dx}{\sin x}$ និង $J=\int_{\frac{\pi}{4}}^{\frac{\pi}{2}}\frac{dx}{\sin^3 x}$

ក-កំនត់ពីរចំនួនពិត a, b ដើម្បីឲ្យ $\frac{1}{\sin x}=\frac{a\sin x}{1+\cos x}+\frac{b\sin x}{1-\cos x}$ ។

ខ-គណនាអាំងតេក្រាល I រួចទាញរកតម្លៃ J ។

៤១_គេមានអនុគមន៍ $f(x)=\frac{e^{4x}+1}{(e^{2x}+1)^2}$ ដែល x ជាចំនួនពិត ។

ក-កំនត់បីចំនួនពិត A , B ដើម្បីឲ្យ $f(x)=A+\frac{B.e^{2x}}{(e^{2x}+1)^2}$ ។

ខ-គណនាអាំងតេក្រាល $I=\int_{0}^{\frac{1}{2}}f(x).dx$ ។

៥២_គេឱ្យអនុគមន៍ $f(x)=\frac{2x^2+4x+3}{(x+1)(x+2)^2}$ ។

ក-កំនត់បីចំនួនពិត $A,B$ និង $C$ ដើម្បីឱ្យអនុគមន៍ $f(x)$ អាចសរសេរជារាង

$f(x)=\frac{A}{x+1}+\frac{B}{x+2}+\frac{C}{(x+2)^2}$ ។

ខ-គណនាអាំងតេក្រាល $I=\int_0^1 f(x).dx$ ។

៥៣_គេឱ្យអនុគមន៍ $f(x)=\frac{e^x-1}{e^x+1}$ កំនត់លើ IR ។

ក-ចូរសរសេរ $f(x)$ ជារាង $f(x)=A+\frac{B.e^{-x}}{1+e^{-x}}$

ខ-គណនាអាំងតេក្រាល $I=\int_0^1 f(x).dx$

ដោយសរសេរលទ្ធផលជារាង $a+\ln b$ ដែល $a$ និង $b$ ជាពីរចំនួនពិតត្រូវរក

៥៤_គេឱ្យអនុគមន៍ $f(x)=(x^2+x-7).e^x$ កំនត់លើ IR ។

ក-កំនត់ចំនួនពិត $a,b$ និង $c$ ដើម្បីឱ្យអនុគមន៍ $F(x)=(ax^2+bx+c).e^x$

ជាព្រីមីទីវនៃអនុគមន៍ $f(x)$ ។

ខ-គណនាអាំងតេក្រាល $I=\int_0^3 f(x).dx$

៤៥_គេឱ្យអនុគមន៍ $f(x)=\frac{1}{x^2-1}$

ក-កំនត់ចំនួនពិត A និង B ដើម្បីឱ្យ $f(x)=\frac{A}{x-1}+\frac{B}{x+1}$

ខ-គណនាអាំងតេក្រាល $I=\int_2^5 f(x).dx$ ។

៤៦_គេដឹងថា $\int_0^{x^2} f(2t-1).dt = 4x^6$ ។ចូររកអនុគមន៍ $f(x)$ ។

៤៧១.ដោះស្រាយសមីការ $g''(x)-5g'(x)+6g(x)=0 \ (E)$

២. កំនត់ចំលើយ $g(x)$ មួយនៃសមីការ $(E)$ ដែល $g(0)=0$ និង $g'(0)=1$

៤៨_ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''-3y'+2y=0$

ដោយដឹងថា $y(0)=1 \ , y'(0)=0$ ។

៤៩_គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y''-4y'+4y=4x^2-24x+34$

ក-កំនត់ចំនួនពិត $a,b$ និង $c$ ដើម្បីឱ្យអនុគមន៍ $y_P(x)=ax^2+bx+c$

ជាចំលើយដោយឡែកមួយរបស់សមីការ $(E)$ ។

ខ-បង្ហាញថាអនុគមន៍ $y=y_P(x)+y_h(x)$ ជាចំលើយទូទៅរបស់ $(E)$

លុះត្រាតែអនុគមន៍ $y_h(x)$ ជាចំលើយរបស់សមីការអូម៉ូសែន

$(E'): y''-4y'+4y=0$ ។

គ-ដោះស្រាយសមីការ $(E')$ រួចទាញរកចំលើយទូទៅរបស់សមីការ $(E)$ ។

៥០_ក-ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): f''(x)-f'(x)-6f(x)=0$

ខ-កំនត់អនុគមន៍ $y=f(x)$ ជាចំលើយមួយរបស់សមីការ $(E)$

បើគេដឹងថាខ្សែកោង $(C)$ តាង $f(x)$ ប៉ះទៅនឹងបន្ទាត់ $(T): y=-x+3$

ត្រង់ចំនុច $M(0,3)$ ។

៥១_គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y''+9y=0$

ក-ដោះស្រាយសមីការ $(E)$ ។

ខ-កំនត់អនុគមន៍ $f(x)$ ជាចំលើយមួយរបស់សមីការ $(E)$ បើគេដឹងថា :

$f(0)=\sqrt{3}$ , $f'(0)=3$ ។

៥២_គេឱ្យសមីការឌីផេរ៉ង់ស្យែល : $y''-4y=8x-12$ $(E)$

ក-កំនត់អនុគមន៍ $\varphi(x)=ax+b$ ជាចំលើយដោយឡែកមួយរបស់ $(E)$ ។

ខ-រកចំលើយទូទៅរបស់សមីការ $(E)$ ។

៥៣_គេឱ្យប្រវែងប្រែប្រួលមួយ MN ដែល $MN = f(x)$ ។

អនុគមន៍ $f(x)$ ជាចំលើយសមីការឌីផេរ៉ង់ស្យែល :

$(E): f''(x) - 2f'(x) + f(x) = 0$ ។

ក-គណនាប្រវែង MN បើគេដឹងថា $f(0) = 2$ និង $f'(0) = 1$ ។

ខ-កំនត់ប្រវែងអតិបរមានៃ MN ។

៥៤_គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y''+4y = 0$ ។

ក-ដោះស្រាយសមីការ $(E)$ ។

ខ-កំនត់អនុគមន៍ $f(x)$ ជាចំលើយមួយនៃសមីការ $(E)$ បើគេដឹងថា

$f(0) = 1$ និង $f'(0) = 2\sqrt{3}$ ។

គ-ចូរសរសេរអនុគមន៍ $f(x)$ ជារាង $f(x) = k.\cos(\omega x + \varphi)$

ដែល $k$ ,$\omega$ និង $\varphi$ ជាបីចំនួនពិត ។

ឃ-គណនាអាំងតេក្រាល $I = \int_0^{\frac{\pi}{3}} \frac{dx}{f^2(x)}$ ។

៥៥_គេឱ្យអាំងតេក្រាល $I_n = \int_0^1 \frac{e^{nx}}{e^x + 1}.dx , n \in IN$ ។

ក-គណនា $I_0 + I_1$ , $I_1$ រួចទាញរក $I_0$ ។

ខ-គណនា $I_n + I_{n+1}$ ជាអនុគមន៍នៃ n ។

៥៦_គេឱ្យអនុគមន៍ f កំនត់លើ $IR-\{-1\}$ ហើយផ្ទៀងផ្ទាត់ទំនាក់ទំនង:

$$x^2f(x^3)+\frac{1}{(1+x)^2}f\left(\frac{1-x}{1+x}\right)=4x^3(1+x^4)^5$$

ចូរគណនាអាំងតេក្រាល: $I=\int_0^1 f(x).dx$ ។

៥៧_គេសន្មត់ថា f ជាអនុគមន៍មួយកំនត់លើ IR ហើយផ្ទៀងផ្ទាត់ទំនាក់ទំនង:

$$f(x)+f(-x)=\sqrt{2-2\cos 2x}$$ ។

ចូរគណនា $I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}} f(x).dx$ ។

៥៨_ចូរបង្ហាញថា $\int_a^b f(x).dx=\int_a^b f(a+b-x).dx$

អនុវត្តន៏ : ចូរគណនា $I=\int_0^{\frac{\pi}{3}}\log_2(1+\sqrt{3}\tan x).dx$

៥៩_គេឱ្យ f ជាអនុគមន៍ជាប់លើ $[0,1]$ ។

ចូរបង្ហាញថា $\int_0^{\pi} x.f(\sin x).dx=\frac{\pi}{2}\int_0^{\pi} f(\sin x).dx$ ?

អនុវត្តន៏: ចូរគណនា $I=\int_0^{\pi}\frac{x\sin x.dx}{1+\cos^2 x}$ ។

៦០_គេឱ្យ f ជាអនុគមន៍គូលើ $[-a,a]$ ។

ក. ចូរបង្ហាញថា $\int_{-a}^{a} \frac{f(x).dx}{1+q^x} = \int_{0}^{a} f(x).dx$ , $q > 0$ , $q \neq 1$ ។

ខ. អនុវត្តន៍ ៖ គណនា $I = \int_{-\frac{\pi}{2}}^{\frac{\pi}{2}} \frac{\cos x}{1+3^x}.dx$

៦១_ក-គណនាអាំងតេក្រាលកំនត់ $I_n = \int_0^1 (1+x)^n.dx$ , $n \in IN$ ។

ខ-ទាញបង្ហាញថា $C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + ..... + \frac{1}{n+1}C_n^n = \frac{2^{n+1}-1}{n+1}$

៦២_គេមានស្វ៊ីត $(I_n)$ កំនត់ចំពោះគ្រប់ $n \geq 1$ ដោយ

$$I_n = \frac{1}{n!}.\int_0^1 (1-x)^n.e^x.dx$$

ក-ចូរគណនាតួ $I_1$ ។

ខ-ចូរបញ្ជាក់ $I_{n+1}$ ជាអនុគមន៍នៃ $I_n$ រួចទាញឱ្យបានថា $I_n = e - \sum_{p=0}^{n}\left(\frac{1}{P!}\right)$

គ-ចូររកលីមីត $\lim_{n\to+\infty} I_n$ ។

ទាញថា $\lim_{n\to+\infty}\left(1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+....+\frac{1}{n!}\right) = e = 2.71828$ ។

# ផ្នែកដំណោះស្រាយ

## លំហាត់ទី១

គេឲ្យសមីការ $(E): z^2 + iaz + a + ib = 0$ ដែល $a, b \in IR$

ក_កំនត់ a និង b ដើម្បីឲ្យ $z_1 = -1 + i\sqrt{3}$ ជាឫសមួយរបស់សមីការ (E) រួចគណនាឫសមួយទៀត $z_2$ ។

ខ_ចូរសរសេរ $z_1$ , $z_2$ និង $\frac{z_1}{z_2}$ ជាទម្រង់ត្រីកោណមាត្រ ។

គ_ទាញបញ្ជាក់តម្លៃប្រាកដនៃ $\cos\frac{5\pi}{12}$ និង $\sin\frac{5\pi}{12}$ ។

## ដំណោះស្រាយ

ក_កំនត់ a និង b ៖

ដើម្បីឲ្យ $z_1 = -1 + i\sqrt{3}$ ជាឫសមួយរបស់ (E)លុះណាតែវាផ្ទៀងផ្ទាត់នឹងសមីការ

គេបាន $(-1 + i\sqrt{3})^2 + ia(-1 + i\sqrt{3}) + a + ib = 0$

$$1 - 2\sqrt{3}\,i - 3 - ia - a\sqrt{3} + a + ib = 0$$

$$(-2 + a - a\sqrt{3}) + i(-2\sqrt{3} - a + b) = 0$$

គេទាញ $\begin{cases} -2 + a - a\sqrt{3} = 0 \\ -2\sqrt{3} - a + b = 0 \end{cases}$ ដោះស្រាយប្រព័ន្ធគេបាន ៖

ដូចនេះ $\boxed{a = \frac{2}{1 - \sqrt{3}} = -1 - \sqrt{3} \text{ និង } b = -1 + \sqrt{3}}$

គណនាឫសមួយទៀត $z_2$ ៖

ដោយ $z_1$ និង $z_2$ ជាឫសរបស់សមីការ (E)

នោះតាមទ្រឹស្តីបទវ្យែតយើងបាន $z_1 + z_2 = -ia$ នាំឲ្យ

$$z_2 = -ia - z_1 = -i(-1-\sqrt{3}) - (-1+i\sqrt{3}) = 1+i$$

ដូចនេះ $z_2 = 1+i$ ។

ខ-សរសេរ $z_1$ , $z_2$ និង $\frac{z_2}{z_1}$ ជាទម្រង់ត្រីកោណមាត្រ ៖

យើងបាន $z_1 = -1+i\sqrt{3} = 2(-\frac{1}{2}+i.\frac{\sqrt{3}}{2}) = 2(\cos\frac{2\pi}{3}+i.\sin\frac{2\pi}{3})$

$$z_2 = 1+i = \sqrt{2}(\frac{\sqrt{2}}{2}+i.\frac{\sqrt{2}}{2}) = \sqrt{2}(\cos\frac{\pi}{4}+i.\sin\frac{\pi}{4})$$

និង $\frac{z_1}{z_2} = \frac{2}{\sqrt{2}}\left[\cos(\frac{2\pi}{3}-\frac{\pi}{4})+i.\sin(\frac{2\pi}{3}-\frac{\pi}{4})\right] = \sqrt{2}(\cos\frac{5\pi}{12}+i.\sin\frac{5\pi}{12})$ ។

គ-ទាញបញ្ជាក់តម្លៃប្រាកដនៃ $\cos\frac{5\pi}{12}$ និង $\sin\frac{5\pi}{12}$

តាមសម្រាយខាងលើយើងមាន $\frac{z_1}{z_2} = \sqrt{2}(\cos\frac{5\pi}{12}+i.\sin\frac{5\pi}{12})$ (1)

ម្យ៉ាងទៀត $\frac{z_1}{z_2} = \frac{-1+i\sqrt{3}}{1+i} = \frac{(-1+i\sqrt{3})(1-i)}{2} = \frac{\sqrt{3}-1}{2}+i\frac{\sqrt{3}+1}{2}$ (2)

តាម (1) និង (2) គេទាញបាន ៖

$\cos\frac{5\pi}{12} = \frac{\sqrt{3}-1}{2\sqrt{2}} = \frac{\sqrt{6}-\sqrt{2}}{4}$ និង $\sin\frac{5\pi}{12} = \frac{\sqrt{3}+1}{2\sqrt{2}} = \frac{\sqrt{6}+\sqrt{2}}{4}$

**លំហាត់ទី២**

គេឲ្យអនុគមន៍ $f(x)$ កំនត់លើ IR ដោយ ÷

$$f(x)=\ln(x^2-x\sqrt{2}+1)-\ln(x^2+x\sqrt{2}+1)$$

ក_ចូរគណនាតម្លៃ $f(-\sqrt{2})$ , $f(0)$ និង $f(\sqrt{2})$ ។

បង្ហាញថា $f(x)$ជាអនុគមន៍សេស ។

ខ_គណនាដេរីវេ $f'(x)$ និង $f''(x)$ ។

**ដំណោះស្រាយ**

ក.គណនាតម្លៃ $f(-\sqrt{2})$ , $f(0)$ និង $f(\sqrt{2})$

មាន $f(x)=\ln(x^2-x\sqrt{2}+1)-\ln(x^2+x\sqrt{2}+1)$

យើងបាន $f(-\sqrt{2})=\ln(2+2+1)-\ln(2-2+1)=\ln 5$

$$f(0)=\ln(0-0+1)-\ln(0+0+1)=0$$

$$f(\sqrt{2})=\ln(2-2+1)-\ln(2+2+1)=-\ln 5$$

ដូចនេះ $\boxed{f(-\sqrt{2})=\ln 5\ ,\ f(0)=0\ ,f(\sqrt{2})=\ln 5}$

បង្ហាញថា $f(x)$ ជាអនុគមន៍សេស ÷

យើងមាន $x\in IR$ និង $-x\in IR$

យើងបាន $f(-x)=\ln(x^2+x\sqrt{2}+1)-\ln(x^2-x\sqrt{2}+1)=-f(x)$

ដូចនេះ $f(x)$ ជាអនុគមន៍សេស ។

ខ_គណនាដេរីវេ $f'(x)$និង $f''(x)$

យើងបាន $f'(x)=\dfrac{(x^2-x\sqrt{2}+1)'}{(x^2-x\sqrt{2}+1)}-\dfrac{(x^2+x\sqrt{2}+1)'}{(x^2+x\sqrt{2}+1)}$

$$=\frac{2x-\sqrt{2}}{x^2-x\sqrt{2}+1}-\frac{2x+\sqrt{2}}{x^2+x\sqrt{2}+1}$$

$$=\frac{(2x-\sqrt{2})(x^2+x\sqrt{2}+1)-(2x+\sqrt{2})(x^2-x\sqrt{2}+1)}{(x^2-x\sqrt{2}+1)(x^2+x\sqrt{2}+1)}$$

$$=\frac{2\sqrt{2}\ x^2-2\sqrt{2}}{x^4+1}=\frac{2\sqrt{2}(x^2-1)}{x^4+1}$$

ដូចនេះ $\boxed{f'(x)=2\sqrt{2}\ \dfrac{x^2-1}{x^4+1}}$ ។

ម្យ៉ាងទៀត $f''(x)=2\sqrt{2}\ \dfrac{(x^2-1)'(x^4+1)-(x^4+1)'(x^2-1)}{(x^4+1)^2}$

$$=2\sqrt{2}\ \frac{2x(x^4+1)-4x^3(x^2-1)}{(x^4+1)^2}$$

$$=2\sqrt{2}\ \frac{2x^5+2x-4x^5+4x^3}{(x^4+1)^2}$$

$$=-4\sqrt{2}\ \frac{x\ (x^4-2x^2-1)}{(x^4+1)^2}$$

ដូចនេះ $\boxed{f''(x)=-4\sqrt{2}\ \dfrac{x\ (x^4-2x^2-1)}{(x^4+1)^2}}$ ។

## លំហាត់ទី៣

គេឲ្យចំនួនកុំផ្លិច $z = x + i.y$ ដែល x និង y ជាពីរចំនួនពិត ។

ចូរកំនត់តម្លៃ x និង y បើគេដឹងថា៖

$$(3+2i)z + (1+3i)\bar{z} = \frac{10}{2-i}$$

( $\bar{z}$ ជាចំនួនកុំផ្លិចឆ្លាស់នៃ z ) ។

## ដំណោះស្រាយ

កំនត់តម្លៃ x និង y

គេមាន $(3+2i)z + (1+3i)\bar{z} = \frac{10}{2-i}$

ដោយ $z = x + i.y$ នាំឲ្យ $\bar{z} = x - i.y$

គេបាន $(3+2i)(x+iy) + (1+3i)(x-iy) = \frac{10}{2-i}$

$$3x + 3iy + 2ix - 2y + x - iy + 3ix + 3y = \frac{10(2+i)}{5}$$

$$(4x+y) + i.(5x+2y) = 4 + 2i$$

គេទាញបាន $\begin{cases} 4x + y = 4 \\ 5x + 2y = 2 \end{cases}$

គេមាន $D = \begin{vmatrix} 4 & 1 \\ 5 & 2 \end{vmatrix} = 8 - 5 = 3$ , $D_x = \begin{vmatrix} 4 & 1 \\ 2 & 2 \end{vmatrix} = 8 - 2 = 6$

និង $D_y = \begin{vmatrix} 4 & 4 \\ 5 & 2 \end{vmatrix} = 8 - 20 = -12$

គេបាន $x = \frac{D_x}{D} = \frac{6}{3} = 2$ , $y = \frac{D_y}{D} = -\frac{12}{3} = -4$

ដូចនេះ $\boxed{x = 2 , y = -4}$ ។

**លំហាត់ទី៤**

គេអោយចំនួនកុំផ្លិច $z = \cos\frac{4\pi}{7} + i.\sin\frac{4\pi}{7}$ ។

ចូរសរសេរ $(1+z)^4$ ជារាងត្រីកោណមាត្រ ។

**ដំណោះស្រាយ**

សរសេរ $(1+z)^4$ ជារាងត្រីកោណមាត្រ៖

គេបាន $1 + z = 1 + \cos\frac{4\pi}{7} + i.\sin\frac{4\pi}{7}$

ដោយ $\begin{cases} 1 + \cos\frac{4\pi}{7} = 2\cos^2\frac{2\pi}{7} \\ \sin\frac{4\pi}{7} = 2\sin\frac{2\pi}{7}\cos\frac{2\pi}{7} \end{cases}$

គេទាញ

$$1 + z = 2\cos^2\frac{2\pi}{7} + 2i.\sin\frac{2\pi}{7}\cos\frac{2\pi}{7} = 2\cos\frac{2\pi}{7}(\cos\frac{2\pi}{7} + i.\sin\frac{2\pi}{7})$$

តាមរូបមន្តដឺមរ័គេអាចសរសេរ៖

$$(1+z)^4=\left[2\cos\frac{2\pi}{7}(\cos\frac{2\pi}{7}+i.\sin\frac{2\pi}{7})\right]^4$$

$$=16\cos^4\frac{2\pi}{7}\left(\cos\frac{8\pi}{7}+i.\sin\frac{8\pi}{7}\right)$$

ដូចនេះ $\boxed{(1+z)^4=16\cos^4\frac{2\pi}{7}\left(\cos\frac{8\pi}{7}+i.\sin\frac{8\pi}{7}\right)}$ ។

## លំហាត់ទី៥

គេអោយចំនួនកុំផ្លិច : $z_1=\frac{\sqrt{6}-i.\sqrt{2}}{2}$ និង $z_2=1-i$

ក.ចូរសរសេរ $z_1$ ,$z_2$ និង $Z=\frac{z_1}{z_2}$ ជារាងត្រីកោណមាត្រ ។

ខ.ចូរសរសេរ $Z=\frac{z_1}{z_2}$ ជារាងពិជគណិត ។

គ.ទាញអោយបានថា $\cos\frac{\pi}{12}=\frac{\sqrt{6}+\sqrt{2}}{4}$ និង $\sin\frac{\pi}{12}=\frac{\sqrt{6}-\sqrt{2}}{4}$ ។

## ដំណោះស្រាយ

ក.សរសេរ $z_1$ ,$z_2$ និង $Z=\frac{z_1}{z_2}$ ជារាងត្រីកោណមាត្រៈ

គេមាន $z_1=\frac{\sqrt{6}-i\sqrt{2}}{2}=\sqrt{2}\left(\frac{\sqrt{3}}{2}-i.\frac{1}{2}\right)=\sqrt{2}\left(\cos\frac{\pi}{6}-i.\sin\frac{\pi}{6}\right)$

ដូចនេះ $\boxed{z_1=\sqrt{2}\left[\cos(-\frac{\pi}{6})+i.\sin(-\frac{\pi}{6})\right]}$ ។

គេមាន $z_2 = 1 - i = \sqrt{2}\left(\frac{\sqrt{2}}{2} - i.\frac{\sqrt{2}}{2}\right) = \sqrt{2}\left(\cos\frac{\pi}{4} - i.\sin\frac{\pi}{4}\right)$

ដូចនេះ $\boxed{z_2 = \sqrt{2}\left[\cos(-\frac{\pi}{4}) + i.\sin(-\frac{\pi}{4})\right]}$ ។

គេមាន $Z = \frac{z_1}{z_2} = \frac{\sqrt{2}}{\sqrt{2}}\left[\cos(-\frac{\pi}{6} + \frac{\pi}{4}) + i.\sin(-\frac{\pi}{6} + \frac{\pi}{4})\right]$

ដូចនេះ $\boxed{Z = \cos\frac{\pi}{12} + i.\sin\frac{\pi}{12}}$ ។

ខ. សរសេរ $Z = \frac{z_1}{z_2}$ ជារាងពិជគណិត

គេបាន $Z = \frac{\sqrt{6} - i\sqrt{2}}{2(1-i)} = \frac{(\sqrt{6} - i\sqrt{2})(1+i)}{2(1-i)(1+i)} = \frac{\sqrt{6} + i\sqrt{6} - i\sqrt{2} + \sqrt{2}}{4}$

ដូចនេះ $\boxed{Z = \frac{\sqrt{6} + \sqrt{2}}{4} + i.\frac{\sqrt{6} - \sqrt{2}}{4}}$ ។

គ. ទាញអោយបានថា $\cos\frac{\pi}{12} = \frac{\sqrt{6} + \sqrt{2}}{4}$ និង $\sin\frac{\pi}{12} = \frac{\sqrt{6} - \sqrt{2}}{4}$

តាមសម្រាយខាងលើគេមាន :

$Z = \cos\frac{\pi}{12} + i.\sin\frac{\pi}{12}$ (1) និង $Z = \frac{\sqrt{6} + \sqrt{2}}{4} + i.\frac{\sqrt{6} - \sqrt{2}}{4}$ (2)

ផ្ទឹមទំនាក់ទំនង (1) និង (2) គេបាន :

$$\cos\frac{\pi}{12} + i.\sin\frac{\pi}{12} = \frac{\sqrt{6} + \sqrt{2}}{4} + i.\frac{\sqrt{6} - \sqrt{2}}{4}$$

ដូចនេះ $\boxed{\cos\frac{\pi}{12} = \frac{\sqrt{6} + \sqrt{2}}{4}}$ និង $\boxed{\sin\frac{\pi}{12} = \frac{\sqrt{6} - \sqrt{2}}{4}}$ ។

## លំហាត់ទី៦

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to 0}\dfrac{e^x+2\sin x-1}{x}$ ខ. $\lim\limits_{n\to+\infty}\left(\dfrac{2n}{2n-1}\right)^{n+1}$

## ដំណោះស្រាយ

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to 0}\dfrac{e^x+2\sin x-1}{x}$

$$=\lim_{x\to 0}\left(\frac{e^x-1}{x}+2\frac{\sin x}{x}\right)$$

$$=\lim_{x\to 0}\frac{e^x-1}{x}+2\lim_{x\to 0}\frac{\sin x}{x}=1+2=3$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{e^x+2\sin x-1}{x}=3}$ ។

ខ. $\lim\limits_{n\to+\infty}\left(\dfrac{2n}{2n-1}\right)^{n+1}$

$$=\lim_{n\to+\infty}\left(1+\frac{1}{2n-1}\right)^{n+1}$$

$$=\lim_{n\to+\infty}\left(\left(1+\frac{1}{2n-1}\right)^{2n-1}\right)^{\frac{n+1}{2n-1}}=e^{\frac{1}{2}}=\sqrt{e}$$

ដូចនេះ $\boxed{\lim\limits_{n\to+\infty}\left(\dfrac{2n}{2n-1}\right)^{n+1}=\sqrt{e}}$ ។

## លំហាត់ទី៧

ចូរគណនាលីមីត ៖

ក. $\lim_{x\to 0}\frac{e^{-x^2}-\cos x}{x^2}$

ខ. $\lim_{x\to 0}\frac{e^x-e^{-x}}{\sin x}$

## ដំណោះស្រាយ

គណនាលីមីត

ក. $\lim_{x\to 0}\frac{e^{-x^2}-\cos x}{x^2}$

$$=\lim_{x\to 0}\frac{(e^{-x^2}-1)+(1-\cos x)}{x^2}=\lim_{x\to 0}\frac{e^{-x^2}-1+2\sin^2\frac{x}{2}}{x^2}$$

$$=\lim_{x\to 0}\frac{e^{-x^2}-1}{x^2}+\lim_{x\to 0}\frac{2\sin^2\frac{x}{2}}{x^2}=-1+\frac{1}{2}=-\frac{1}{2}$$

ដូចនេះ $\boxed{\lim_{x\to 0}\frac{e^{-x^2}-\cos x}{x^2}=-\frac{1}{2}}$

ខ. $\lim_{x\to 0}\frac{e^x-e^{-x}}{\sin x}$

$$=\lim_{x\to 0}\frac{(e^x-1)-(e^{-x}-1)}{\sin x}=\lim_{x\to 0}\frac{e^x-1}{\sin x}-\lim_{x\to 0}\frac{e^{-x}-1}{\sin x}$$

$$=\lim_{x\to 0}\frac{e^x-1}{x}.\frac{x}{\sin x}+\lim_{x\to 0}\frac{e^{-x}-1}{-x}.\frac{x}{\sin x}=1+1=2$$

ដូចនេះ $\boxed{\lim_{x\to 0}\frac{e^x-e^{-x}}{\sin x}=2}$ ។

## លំហាត់ទី៨

ចូរគណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{n\to+\infty}\left(1+\frac{1}{n}\right)^{n+5}$ ខ. $\lim\limits_{n\to+\infty}\left(\frac{n-1}{n+1}\right)^{n+2}$

## ដំណោះស្រាយ

គណនាលីមីត ៖

ក. $\lim\limits_{n\to+\infty}\left(1+\frac{1}{n}\right)^{n+5}$

តាង $x=\frac{1}{n}$ កាលណា $n\to+\infty$ នោះ $x\to 0$

គេបាន $\lim\limits_{n\to+\infty}\left(1+\frac{1}{n}\right)^{n+5} = \lim\limits_{x\to0}(1+x)^{\frac{1}{x}+5} = \lim\limits_{x\to0}(1+x)^{\frac{1}{x}}.(1+x)^5 = e$

ដូចនេះ $\boxed{\lim\limits_{n\to+\infty}\left(1+\frac{1}{n}\right)^{n+5} = e}$ ។

ខ. $\lim\limits_{n\to+\infty}\left(\frac{n-1}{n+1}\right)^{n+2}$

តាង $1+x=\frac{n-1}{n+1}$ នាំឲ្យ $x=-\frac{2}{n+1}$ និង $n=-\frac{2+x}{x}$

កាលណា $n\to+\infty$ នោះ $x\to 0$

គេបាន $\lim\limits_{n\to+\infty}\left(\frac{n-1}{n+1}\right)^{n+2} = \lim\limits_{x\to0}(1+x)^{-\frac{2+x}{x}+2} = \lim\limits_{x\to0}(1+x)^{-\frac{2}{x}+1}$

$$= \lim_{x\to 0}\left[(1+x)^{\frac{1}{x}}\right]^{-2}.(1+x) = e^{-2} = \frac{1}{e^2}$$

ដូចនេះ $\boxed{\lim_{n\to+\infty}\left(\frac{n-1}{n+1}\right)^{n+2} = \frac{1}{e^2}}$ ។

## លំហាត់ទី៩

កំនត់ចំនួនពិត x និង y ដើម្បីអោយ $(x+1)+(3+2y).i = \frac{7+9i}{3+2i}$

## ដំណោះស្រាយ

កំនត់ចំនួនពិត x និង y

គេមាន $(x+1)+(3+2y).i = \frac{7+9i}{3+2i}$

$$= \frac{(7+9i)(3+2i)}{(3+2i)(3-2i)}$$

$$= \frac{21-14i+27i-18i^2}{9-4i^2}$$

$$= \frac{39+13i}{13} = 3+i$$

គេបាន $\begin{cases} x+1=3 \\ 3+2y=1 \end{cases}$ នាំអោយ $\begin{cases} x=2 \\ y=-1 \end{cases}$

ដូចនេះ $\boxed{x=2, y=-1}$ ។

## លំហាត់ទី១០

គេអោយ $f(z)=z^3-2(\sqrt{3}+i).z^2+4(1+i\sqrt{3}).z-8i$

ក.ចូរបង្ហាញថា $\forall z\in\mathbb{C}$ $f(z)=(z-2i)(z^2-2\sqrt{3}z+4)$

ខ.ដោះស្រាយសមីការ $f(z)=0$ ក្នុងសំណុំកុំផ្លិច ។

## ដំណោះស្រាយ

ក. បង្ហាញថា $\forall z\in\mathbb{C}$ : $f(z)=(z-2i)(z^2-2\sqrt{3}z+4)$

យើងមាន $f(z)=(z-2i).(z^2-2\sqrt{3}z+4)$

ដោយពន្លាតអនុគមន៍នេះយើងបាន :

$$\begin{aligned} f(z) &= z^3-2\sqrt{3}z+4z-2i(z^2-2\sqrt{3}z+4) \\ &= z^3-2\sqrt{3}.z^2+4z-2iz^2+4\sqrt{3}iz-8i \\ &= z^3-2(\sqrt{3}+i).z^2+4(1+i\sqrt{3}).z-8i \quad \text{ពិត} \end{aligned}$$

ដូចនេះ $\boxed{\forall z\in\mathbb{C}\ f(z)=(z-2i)(z^2-2\sqrt{3}z+4)}$ ។

ខ. ដោះស្រាយសមីការ

បើ $f(z)=0$ នាំអោយ $(z-2i).(z^2-2\sqrt{3}.z+4)=0$

គេទាញឫស $z=2i$ ហើយ $,z^2-2\sqrt{3}.z+4=0$ $,\Delta'=3-4=-1=i^2$

នាំអោយ $z_1=\sqrt{3}+i$ $,z_2=\sqrt{3}-i$ ។

## លំហាត់ទី១១

ចូរគណនាលីមីត :

ក. $\lim\limits_{x\to 0}\dfrac{1-\cos 2x + x\sin 2009x}{x^2}$

ខ. $\lim\limits_{x\to 3}\dfrac{x^3-3x^2+(a-1)x+3-3a}{x^2-4x+3}$

## ដំណោះស្រាយ

ក. $\lim\limits_{x\to 0}\dfrac{1-\cos 2x + x\sin 2009x}{x^2}$ ដោយ $1-\cos 2x = 2\sin^2 x$

$$= \lim_{x\to 0}\frac{2\sin^2 x + x\sin 2009x}{x^2}$$

$$= \lim_{x\to 0}\left(2.\frac{\sin^2 x}{x^2} + \frac{\sin 2009x}{2009x}.2009\right)$$

$$= 2 + 2009 = 2011.$$

ខ. $\lim\limits_{x\to 3}\dfrac{x^3-3x^2+(a-1)x+3-3a}{x^2-4x+3}$

$$= \lim_{x\to 3}\frac{(x^3-3x^2)+(a-1)x-3(a-1)}{(x^2-x)-(3x-3)}$$

$$= \lim_{x\to 3}\frac{x^2(x-3)+(a-1)(x-3)}{x(x-1)-3(x-1)} = \lim_{x\to 3}\frac{(x-3)(x^2+a-1)}{(x-1)(x-3)}$$

$$= \lim_{x\to 3}\frac{x^2+a-1}{x-1} = \frac{9+a-1}{3-1} = \frac{a+8}{2}.$$

## លំហាត់ទី១២

គេអោយអនុគមន៍ $f(x)=x^3-6x^2+9x-3$

ក.បង្ហាញថាមានតំលៃ $x_0$ ដែល $1<x_0<2$ ហើយ $f(x_0)=0$ ។

ខ.គណនាដេរីវេ $f'(x)$ ហើយសិក្សាសញ្ញានៃ $f'(x)$ ។

សង់តារាងអថេរភាពនៃ $f(x)$ ។

## ដំណោះស្រាយ

ក-បង្ហាញថាមានតំលៃ $x_0$ ដែល $1<x_0<2$ ហើយ $f(x_0)=0$

$f(x)$ ជាអនុគមន៍កំនត់ជាប់លើ IR

គេមាន $f(1)=1^3-6.1^2+9.1-3=1$ និង $f(2)=2^3-6.2^2+9.2-3=-1$

ដោយ $f(1).f(2)=-1<0$ តាមទ្រឹស្តីបទតំលៃកណ្តាលមានតំលៃ $x_0$

ដែល $1<x_0<2$ ហើយ $f(x_0)=0$ ។

ខ-គណនាដេរីវេ $f'(x)$ ហើយសិក្សាសញ្ញានៃ $f'(x)$

យើងបាន $f'(x)=3x^2-12x+9$

សមីការ $f'(x)=3x^2-12x+9=0$ មានឬស $x_1=1$ , $x_2=3$ ។

| x | $-\infty$ | 1 | 3 | $+\infty$ |
|---|---|---|---|---|
| $f'(x)$ | | | | |

តាមតារាងខាងលើគេបាន

$f'(x) > 0$ ចំពោះ $x \in ]-\infty , 1[ \cup ]3 , +\infty[$

$f'(x) < 0$ ចំពោះ $x \in ]1 , 3[$ ។

សង់តារាងអថេរភាពនៃ $f(x)$

គេមាន $f(1) = 1$ និង $f(3) = -3$



## លំហាត់ទី១៣

គេមានអនុគមន៍ $f(x)=\sqrt{3x+1}$ កំនត់លើ $\left[-\frac{1}{3},+\infty\right[$

ក. ចំពោះគ្រប់ $x\in[1,5]$ ចូរបង្ហាញថា $\frac{3}{8}\le f'(x)\le\frac{3}{4}$ ។

ខ. ដោយប្រើវិសមភាពកំណើនមានកំនត់ទៅនឹងអនុគមន៍ f ចំពោះគ្រប់ $x\in[1,5]$ ចូរបង្ហាញថា $\frac{3}{8}x+\frac{13}{8}\le\sqrt{3x+1}\le\frac{3}{4}x+\frac{5}{4}$

## ដំណោះស្រាយ

ក. ចំពោះគ្រប់ $x\in[1,5]$ បង្ហាញថា $\frac{3}{8}\le f'(x)\le\frac{3}{4}$

គេមាន $f(x)=\sqrt{3x+1}$ នាំឱ្យ $f'(x)=\frac{3}{2\sqrt{3x+1}}$

ចំពោះគ្រប់ $x\in[1,5]$ គេមាន $1\le x\le 5$ ឬ $4\le 3x+1\le 16$

$$\frac{1}{4}\le\frac{1}{\sqrt{3x+1}}\le\frac{1}{2}$$

$$\frac{3}{8}\le\frac{3}{2\sqrt{3x+1}}\le\frac{3}{4}$$

ដូចនេះ $\boxed{\frac{3}{8}\le f'(x)\le\frac{3}{4}}$ ចំពោះគ្រប់ $x\in[1,5]$ ។

ខ. បង្ហាញថា $\frac{3}{8}x+\frac{13}{8} \le \sqrt{3x+1} \le \frac{3}{4}x+\frac{5}{4}$

ចំពោះគ្រប់ $x\in[1,5]$ គេមាន $\frac{3}{8}\le f'(x)\le\frac{3}{4}$ ។

តាមទ្រឹស្តីបទវិសមភាពកំណើនមានកំនត់

ចំពោះ $x\ge 1$ គេមាន $\frac{3}{8}(x-1)\le f(x)-f(1)\le\frac{3}{4}(x-1)$

ដោយ $f(x)=\sqrt{3x+1}$

គេបាន $\frac{3}{8}x-\frac{3}{8}\le\sqrt{3x+1}-2\le\frac{3}{4}x-\frac{3}{4}$

នាំឱ្យ $\frac{3}{8}x+\frac{13}{8} \le \sqrt{3x+1} \le \frac{3}{4}x+\frac{5}{4}$ ។

ដូចនេះ $\boxed{\frac{3}{8}x+\frac{13}{8} \le \sqrt{3x+1} \le \frac{3}{4}x+\frac{5}{4}}$ ។

## លំហាត់ទី១៤

គេឱ្យអនុគមន៍ $f(x)=ax+2+b.\ln x$ កំនត់លើចន្លោះ $]0,+\infty[$

ចូរកំនត់ចំនួនពិត a និង b ដើម្បីឱ្យខ្សែកោង (c) តាងអនុគមន៍ $y=f(x)$

ប៉ះនឹងបន្ទាត់ $(T): y=2x-3$ ត្រង់ចំនុច $A(1,-2)$ ។

## ដំណោះស្រាយ

កំនត់ចំនួនពិត a និង b

ដើម្បីឱ្យខ្សែកោង (c) តាងអនុគមន៍ អនុគមន៍ $y=f(x)$ ប៉ះនឹងបន្ទាត់

$(T): y = 2x - 3$ ត្រង់ចំនុច $A(1,-2)$ លុះត្រាតែ $\begin{cases} f'(1) = 2 \\ f(1) = -2 \end{cases}$

គេមាន $f(x) = ax + 2 + b\ln x$ ចំពោះគ្រប់ $x \in \left]0,+\infty\right[$

គេបាន $f'(x) = (ax + 2 + b.\ln x)' = a + \frac{b}{x}$

គេបាន $\begin{cases} f'(1) = a + b = 2 \\ f(1) = a + 2 + b.\ln 1 = -2 \end{cases}$ នាំឱ្យ $\begin{cases} b = 2 - a = 6 \\ a = -4 \end{cases}$

ដូចនេះ $\boxed{a = -4 \ , b = 6}$ ។

## លំហាត់ទី១៥

គេឱ្យអនុគមន៍ $f(x) = \begin{cases} \dfrac{\sin x + \cos x - \sqrt{2}}{(\frac{\pi}{4} - x)^2} & \text{បើ } x \neq \frac{\pi}{4} \\ -\dfrac{\sqrt{2}}{2} & \text{បើ } x = \frac{\pi}{4} \end{cases}$

ចូរសិក្សាភាពជាប់នៃអនុគមន៍ $f$ ត្រង់ចំនុច $x_0 = \frac{\pi}{4}$ ។

## ដំណោះស្រាយ

សិក្សាភាពជាប់នៃអនុគមន៍ $f$ ត្រង់ចំនុច $x_0 = \frac{\pi}{4}$

គេមាន $\lim\limits_{x\to\frac{\pi}{4}} f(x) = \lim\limits_{x\to\frac{\pi}{4}} \dfrac{\sin x + \cos x - \sqrt{2}}{(\frac{\pi}{4} - x)^2}$

តាង $t = \frac{\pi}{4} - x$ នាំឱ្យ $x = \frac{\pi}{4} - t$

កាលណា $x \to \frac{\pi}{4}$ នោះ $t \to 0$

គេបាន $\lim\limits_{x \to \frac{\pi}{4}} f(x) = \lim\limits_{t \to 0} \frac{\sin(\frac{\pi}{4} - t) + \cos(\frac{\pi}{4} - t) - \sqrt{2}}{t^2}$

$$= \lim_{t \to 0} \frac{\sin\frac{\pi}{4}\cos t - \sin t \cos\frac{\pi}{4} + \cos\frac{\pi}{4}\cos t + \sin\frac{\pi}{4}\sin t - \sqrt{2}}{t^2}$$

$$= \lim_{t \to 0} \frac{\frac{\sqrt{2}}{2}\cos t - \frac{\sqrt{2}}{2}\sin t + \frac{\sqrt{2}}{2}\cos t + \frac{\sqrt{2}}{2}\sin t - \sqrt{2}}{t^2}$$

$$= \lim_{t \to 0} \frac{\sqrt{2}\cos t - \sqrt{2}}{t^2} = \lim_{t \to 0} \frac{\sqrt{2}(\cos t - 1)}{t^2} = \frac{-2\sqrt{2}\sin^2\frac{t}{2}}{t^2}$$

$$= -\frac{\sqrt{2}}{2} . \lim_{t \to 0} \frac{\sin^2\frac{t}{2}}{(\frac{t}{2})^2} = -\frac{\sqrt{2}}{2} = f(\frac{\pi}{4})$$

ដោយ $\lim\limits_{x \to \frac{\pi}{4}} f(x) = f(\frac{\pi}{4}) = -\frac{\sqrt{2}}{2}$

នាំឱ្យ $f(x)$ ជាអនុគមន៍ជាប់ត្រង់ $x_0 = \frac{\pi}{4}$ ។

**លំហាត់ទី១៦**

គេឱ្យអនុគមន៍ $f(x)=ax+b-\frac{\ln x}{x}$

ដែល $x>0$ ហើយ a និង b ជាចំនួនពិត។

ក-បង្ហាញថាចំពោះគ្រប់ចំនួនពិត a និង b ដែល $a\neq 0$ ខ្សែកោង $(C)$ តាងអនុគមន៍ $f(x)$ មានអាស៊ីមតូតទ្រេតមួយដែលគេនឹងបញ្ជាក់សមីការ ។

ខ-កំនត់ចំនួនពិត a និង b ដើម្បីឱ្យខ្សែកោង $(C)$ តាងអនុគមន៍ $f(x)$ ប៉ះទៅនឹងបន្ទាត់ $(T): y=x+4$ ត្រង់ចំនុច $A(1,5)$ ។

**ដំណោះស្រាយ**

ក.បង្ហាញថាខ្សែកោង $(C)$ តាងអនុគមន៍ $f(x)$ មានអាស៊ីមតូតទ្រេតមួយ

គេមាន $f(x)=ax+b-\frac{\ln x}{x}$ ដែល $x>0$

ដោយ $\lim\limits_{x\to+\infty}\frac{\ln x}{x}=0$ នាំឱ្យបន្ទាត់ $y=ax+b$ ជាអាស៊ីមតូតទ្រេតនៃ$(C)$ ។

ដូចនេះ ខ្សែកោង $(C)$ តាងអនុគមន៍ $f(x)$ មានអាស៊ីមតូតទ្រេត $y=ax+b$ ។

ខ.កំនត់ចំនួនពិត a និង b

គេមាន $f(x)=ax+b-\frac{\ln x}{x}$

គេបាន $f'(x)=(ax+b)'-\frac{(\ln x)'.x-(x)'.\ln x}{x^2}=a-\frac{1-\ln x}{x^2}$ ។

ដើម្បីឱ្យខ្សែកោង $(C)$ តាងអនុគមន៍ $f(x)$ ប៉ះទៅនឹងបន្ទាត់ $(T): y=x+4$ ។

ត្រង់ចំនុច $A(1,5)$ លុះត្រាតែ $\begin{cases} f'(x_A)=a_T \\ f(x_A)=y_A \end{cases}$

នាំឱ្យ $\begin{cases} a-1=1 \\ a+b=5 \end{cases}$ ឬ $\begin{cases} a=2 \\ b=3 \end{cases}$

ដូចនេះ $\boxed{a=2 \ , b=3}$ ។

**លំហាត់ទី១៧**

គេឱ្យអនុគមន៍ $f(x)=\dfrac{\sin(\pi x)}{1-x^3}$ កំនត់គ្រប់ $x\neq 1$ ។

តើគេអាចបន្លាយអនុគមន៍ $f$ ឱ្យជាប់ត្រង់ចំនុច $x_0=1$ បានឬទេ ?

បើអាច ចូរកំនត់រកអនុគមន៍បន្លាយតាមភាពជាប់នៃអនុគមន៍ $f(x)$

ត្រង់ចំនុច $x_0=1$ ។

**ដំណោះស្រាយ**

កំនត់រកអនុគមន៍បន្លាយតាមភាពជាប់

គេមាន $\lim\limits_{x\to 1} f(x)=\lim\limits_{x\to 1}\dfrac{\sin(\pi x)}{1-x^3}$

តាង $t=1-x$ នាំឱ្យ $x=1-t$ ។

កាលណា $x\to 1$ នោះ $t\to 0$

គេបាន $\lim\limits_{x\to 1} f(x)=\lim\limits_{t\to 0}\dfrac{\sin(\pi-\pi t)}{1-(1-t)^3}$

$$= \lim_{t\to 0}\frac{\sin(\pi t)}{1-1+3t-3t^2+t^3}$$

$$= \lim_{t\to 0}\frac{\sin(\pi t)}{t(3-3t+t^2)}$$

$$= \lim_{t\to 0}\frac{\sin(\pi t)}{\pi t}\cdot\frac{\pi}{3-3t+t^2} = \frac{\pi}{3}$$

ដោយ $\lim_{x\to 1} f(x) = \frac{\pi}{3}$ កំនត់ នោះគេអាចបន្លាយអនុគមន៍ $f(x)$ ឱ្យជាប់ត្រង់ចំនុច $x_0 = 1$ ។

បើយើងតាង $g(x)$ ជាអនុគមន៍បន្លាយតាមភាពជាប់នៃអនុគមន៍ $f(x)$ ត្រង់ចំនុច $x_0 = 1$

ដូចនេះ $g(x) = \begin{cases} f(x) = \dfrac{\sin(\pi x)}{1-x^3} & \text{បើ } x \neq 1 \\ f(1) = \dfrac{\pi}{3} & \text{បើ } x = 1 \end{cases}$

## លំហាត់ទី១៨

គេឱ្យអនុគមន៍ពីរ

$F(x) = (ax^3 + bx^2 + cx + d).e^x$ និង $f(x) = x^3.e^x$ កំនត់លើ IR ។

កំនត់ចំនួនពិត $a, b, c$ និង $d$ ដើម្បីឱ្យ $F(x)$ ជាព្រីមីទីវនៃអនុគមន៍ $f(x)$

**ដំណោះស្រាយ**

កំនត់ចំនួនពិត $a,b,c$ និង $d$

គេមាន $F(x)=(ax^3+bx^2+cx+d).e^x$ និង $f(x)=x^3.e^x$

ដើម្បីឱ្យ $F(x)$ ជាព្រីមីទីវនៃអនុគមន៍ $f(x)$ លើ IR លុះត្រាតែ

$$\forall x\in IR : F'(x)=f(x)$$

$$\begin{aligned} F'(x) &= (ax^3+bx^2+cx+d)'.e^x+(e^x)'.(ax^3+bx^2+cx+d) \\ &= (3ax^2+2bx+c).e^x+e^x.(ax^3+bx^2+cx+d) \\ &= [ax^3+(3a+b)x^2+(2b+c)x+(c+d)].e^x \end{aligned}$$

គេបាន $[ax^3+(3a+b)x^2+(2b+c)x+(c+d)].e^x = x^3.e^x$

គេទាញ $\begin{cases} a=1 \\ 3a+b=0 \\ 2b+c=0 \\ c+d=0 \end{cases}$ នាំឱ្យ $\begin{cases} a=1 \\ b=-3 \\ c=6 \\ d=-6 \end{cases}$

ដូចនេះ $\boxed{a=1\ ,b=-3\ ,c=6\ ,d=-6}$ ។

## លំហាត់ទី១៩

គេឱ្យអនុគមន៍ $f(x) = ax + b - e^x$ មានក្រាបតំនាង $(c)$ ។

កំនត់ចំនួនពិត a និង b ដើម្បីឱ្យខ្សែកោង $(c)$ ប៉ះនឹងបន្ទាត់ $(d): y = x + 3$ ត្រង់ចំនុច $A(0,3)$ ។

## ដំណោះស្រាយ

កំនត់ចំនួនពិត a និង b

គេមាន $f(x) = ax + b - e^x$ នាំអោយ $f'(x) = a - e^x$

ដើម្បីឱ្យខ្សែកោង $(c)$ ប៉ះនឹងបន្ទាត់ $(d): y = x + 3$ ត្រង់ចំនុច $A(0,3)$

លុះត្រាតែ :

$$\begin{cases} f'(0) = 1 \\ f(0) = 3 \end{cases} \text{ នាំអោយ } \begin{cases} a - 1 = 1 \\ b - 1 = 3 \end{cases} \text{ សមមូល } \begin{cases} a = 2 \\ b = 4 \end{cases}$$

ដូចនេះ $\boxed{a = 2 \ , b = 4}$ ។

## លំហាត់ទី២០

គេឱ្យអនុគមន៍ $f(x) = ax + b - x.\ln x$ មានក្រាបតំនាង $(c)$ ។

កំនត់ចំនួនពិត a និង b ដើម្បីឱ្យខ្សែកោង $(c)$ ប៉ះនឹងបន្ទាត់ $(d): y = x + 1$ ត្រង់ចំនុច $A(1,2)$ ។

**ដំណោះស្រាយ**

កំនត់ចំនួនពិត a និង b

គេមាន $f(x) = ax + b - x.\ln x$

គេបាន $f'(x) = (ax + b - x\ln x)'$

$$= a - \ln x - 1$$

ដើម្បីឱ្យខ្សែកោង $(c)$ ប៉ះនឹងបន្ទាត់ $(d): y = x + 1$ ត្រង់ចំនុច $A(1,2)$

លុះត្រាតែ :

$\begin{cases} f'(1) = 1 \\ f(1) = 2 \end{cases}$ នាំអោយ $\begin{cases} a - 1 = 1 \\ a + b = 2 \end{cases}$ សមមូល $\begin{cases} a = 2 \\ b = 0 \end{cases}$

ដូចនេះ $\boxed{a = 2 \ \ ,b = 0}$ ។

**លំហាត់ទី២១**

គេឱ្យអនុគមន៍ $f(x) = \dfrac{x^2 + mx + 4}{x^2 + 1}$

ដែល x ជាចំនួនពិត និង m ជាប៉ារ៉ាម៉ែត្រ ។

ក. ចូរកំនត់តម្លៃ m ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាត្រង់ចំនុច $x = 2$ ។

ខ. ចូរកំនត់តម្លៃ m ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាតែមួយគត់ ។

## ដំណោះស្រាយ

ក. កំនត់តម្លៃ $m$

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាត្រង់ចំនុច $x=2$ លុះត្រាតែ $f'(2)=0$

គេមាន $f(x)=\dfrac{x^2+mx+4}{x^2+1}$

តាមរូបមន្ត $\left(\dfrac{u}{v}\right)' = \dfrac{u'v-v'u}{v^2}$

គេបាន $f'(x)=\dfrac{(x^2+mx+4)'(x^2+1)-(x^2+1)'(x^2+mx+4)}{(x^2+1)^2}$

$$=\frac{(2x+m)(x^2+1)-2x(x^2+mx+4)}{(x^2+1)^2}$$

$$=\frac{2x^3+2x+mx^2+m-2x^3-2mx^2-8x}{(x^2+1)^2}$$

$$f'(x)=\frac{-mx^2-6x+m}{(x^2+1)^2}$$

ចំពោះ $x=2$ គេបាន $f'(2)=\dfrac{-4m+12+m}{(4+1)^2}=\dfrac{12-3m}{25}=0$

នាំឱ្យ $\boxed{m=4}$ ។

ខ. កំនត់តម្លៃ m

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃបរមាតែមួយគត់លុះត្រាតែសមីការ

$f'(x)=0$ សមមូល $-mx^2+6x+m=0$ មានឫសតែមួយគត់

ពោលគឺត្រូវឱ្យ $m=0$ ។

**លំហាត់ទី២២**

គេមានអនុគមន៍ $f(x)=\dfrac{3x^2-7x+6}{(x-3)^2(x+1)}$

ក-សរសេរ $f(x)$ ជាទំរង់ $\dfrac{A}{x+1}+\dfrac{B}{x-3}+\dfrac{C}{(x-3)^2}$

រួចគណនាតំលៃ $A,B$ និង $C$ ។

ខ-គណនា $\int_1^2 f(x).dx$ ដោយសរសេរចំលើយជាទំរង់ $a+\ln b$ ដែល $a$ និង $b$

ជាចំនួនសនិទាន ។

**ដំណោះស្រាយ**

ក-សរសេរ $f(x)$ ជាទំរង់ $\dfrac{A}{x+1}+\dfrac{B}{x-3}+\dfrac{C}{(x-3)^2}$

ដោយគេមានអនុគមន៍ $f(x)=\dfrac{3x^2-7x+6}{(x-3)^2(x+1)}$ នោះគេបាន :

$$\frac{A}{x+1}+\frac{B}{x-3}+\frac{C}{(x-3)^2}=\frac{3x^2-7x+6}{(x-3)^2(x+1)}$$

$$\frac{A(x-3)^2+B(x+1)(x-3)+C(x+1)}{(x+1)(x-3)^2}=\frac{3x^2-7x+6}{(x-3)^2(x+1)}$$

$$A(x-3)^2+B(x+1)(x-3)+C(x+1)=3x^2-7x+6\ \ (1)$$

ចំពោះ $x=-1$ តាម (1) គេបាន :

$16A=3+7+6=16$ នាំឱ្យ $A=1$ ។

ចំពោះ $x=3$ តាម (1) គេបាន :

$$A.(3-3)^2+B(3+1)(3-3)+C(3+1)=3(3)^2-7(3)+6$$

$4C=27-21+6=12$ នាំឱ្យ $C=3$ ។

ចំពោះ $x=0$ តាម (1) គេបាន :

$9A-3B+C=6$ នាំឱ្យ $B=2$ ។

ដូចនេះ $f(x)=\frac{1}{x+1}+\frac{2}{x-3}+\frac{3}{(x-3)^2}$

ហើយ $A=1, B=2$ និង $C=3$

ខ-គណនា $\int_1^2 f(x).dx$ ដោយសរសេរចំលើយជាទំរង់ $a+\ln b$

គេបាន $\int_1^2 f(x).dx=\int_1^2\left(\frac{1}{x+1}+\frac{2}{x-3}+\frac{3}{(x-3)^2}\right).dx$

$$= \int_1^2 \left[ \frac{(x+1)'}{(x+1)} + 2.\frac{(x-3)'}{(x-3)} + 3.\frac{(x-3)'}{(x-3)^2} \right].dx$$

$$= \left[ \ln|x+1| + 2\ln|x-3| - \frac{3}{x-3} \right]_1^2$$

$$= [\ln 3 + 2\ln 1 + 3] - \left[ \ln 2 + 2\ln 2 + \frac{3}{2} \right]$$

$$= \ln 3 + 0 + 3 - 3\ln 2 - \frac{3}{2}$$

$$= \ln 3 - \ln 2^3 + \frac{6-3}{2} = \frac{3}{2} + \ln\frac{3}{8}$$

ដូចនេះ $\boxed{\int_1^2 f(x).dx = \frac{3}{2} + \ln\frac{3}{8}}$ ។

## លំហាត់ទី២៣

គេឲ្យអនុគមន៍ $g(x) = \frac{2x^2 - 5x - 1}{x^3 - x}$ ដែល $x \neq 0$ , $x \neq \mp 1$ ។

ក.កំនត់ចំនួនពិត $A, B$ និង $C$ ដើម្បីឲ្យ $g(x) = \frac{A}{x} + \frac{B}{x-1} + \frac{C}{x+1}$

ខ.ចូរគណនា $I = \int g(x).dx$ ។

## ដំណោះស្រាយ

ក. កំនត់ចំនួនពិត $A, B$ និង $C$ ដើម្បីឲ្យ

$$g(x) = \frac{A}{x} + \frac{B}{x-1} + \frac{C}{x+1}$$

យើងបាន $\frac{A}{x}+\frac{B}{x-1}+\frac{C}{x+1}=\frac{2x^2-5x-1}{x^3-x}$

ឬ $A(x-1)(x+1)+Bx(x+1)+Cx(x-1)=2x^2-5x-1$

បើ $x=0$ នោះ $-A=-1$ ឬ $A=1$

បើ $x=-1$ នោះ $2C=6$ ឬ $C=3$

បើ $x=1$ នោះ $2B=-4$ ឬ $B=-2$

ដូចនេះ $\boxed{A=1\ ,\ B=-2\ ,C=3}$ ។

ខ. គណនា $I=\int g(x).dx$

ចំពោះ $A=1\ ,B=-2\ ,C=3$

គេមាន $g(x)=\frac{1}{x}-\frac{2}{x-1}+\frac{3}{x+1}$

គេបាន ៖

$$I=\int\frac{dx}{x}-2\int\frac{dx}{x-1}+3\int\frac{dx}{x+1}$$
$$=\ln|x|-2\ln|x-1|+3\ln|x+1|+C$$

ដូចនេះ

$$\boxed{I=\int g(x).dx=\ln|x|-2\ln|x-1|+3\ln|x+1|+C}$$ ។

## លំហាត់ទី២៤

គេមានអនុគមន៍ $f(x)=\dfrac{2x^2+2x+1}{x^3+x^2}$ ដែល $x\neq 0$ និង $x\neq -1$

ក_កំនត់ចំនួនពិត $A , B , C$ ដើម្បីឲ្យ $f(x)=\dfrac{A}{x}+\dfrac{B}{x^2}+\dfrac{C}{x+1}$ ។

ខ_គណនាអាំងតេក្រាល $I=\int f(x).dx$ ។

## ដំណោះស្រាយ

ក.កំនត់ចំនួនពិត $A , B , C$

គេបាន $\dfrac{2x^2+2x+1}{x^3+x^2}=\dfrac{A}{x}+\dfrac{B}{x^2}+\dfrac{C}{x+1}$

$$\frac{2x^2+2x+1}{x^2(x+1)}=\frac{Ax(x+1)+B(x+1)+Cx^2}{x^2(x+1)}$$

$$2x^2+2x+1=(A+C)x^2+(A+B)x+B$$

គេទាញបាន $\begin{cases}A+C=2\\A+B=2\\B=1\end{cases}$ នាំឲ្យ $A=1 , B=1 , C=1$ ។

ដូចនេះ $\boxed{A=1 , B=1 , C=1}$ ។

ខ_គណនាអាំងតេក្រាល $I=\int f(x).dx$

តាមសម្រាយខាងលើចំពោះ $A=1 , B=1 , C=1$

គេបាន ៖

$$f(x)=\frac{2x^2+2x+1}{x^3+x^2}=\frac{1}{x}+\frac{1}{x^2}+\frac{1}{x+1}$$

យើងបាន $I=\int\left(\frac{1}{x}+\frac{1}{x^2}+\frac{1}{x+1}\right).dx=\int\frac{dx}{x}+\int\frac{dx}{x^2}+\int\frac{dx}{x+1}$

ដូចនេះ $\boxed{I=\ln|x|-\frac{1}{x}+\ln|x+1|+C}$ ។

**<u>លំហាត់ទី២៥</u>**

គេមានអនុគមន៍ $f(x)=\frac{3x^2-7x+6}{(x-3)^2(x+1)}$

ដែល $x\neq -1$ និង $x\neq 3$ ។

ក_កំនត់បីចំនួនពិត $a, b, c$ ដើម្បីឲ្យ $f(x)=\frac{a}{x+1}+\frac{b}{x-3}+\frac{c}{(x-3)^2}$

ខ_គណនាអាំងតេក្រាល $I=\int_0^1 f(x).dx$ ។

**<u>ដំណោះស្រាយ</u>**

កំនត់បីចំនួនពិត $a, b, c$

គេបាន $\frac{3x^2-7x+6}{(x-3)^2(x+1)}=\frac{a}{x+1}+\frac{b}{x-3}+\frac{c}{(x-3)^2}$

ឬ $3x^2-7x+6=a(x-3)^2+b(x+1)(x-3)+c(x+1)$

ចំពោះ $x=-1$ គេបាន $16=16a$ នាំឲ្យ $a=1$

ចំពោះ $x=3$ គេបាន $12=4c$ នាំឲ្យ $c=3$

ចំពោះ $x=0$ គេបាន $6=9a-3b+c$ នាំឲ្យ $b=\frac{9a+c-6}{3}=2$

ដូចនេះ $\boxed{a=4\ ,\ b=2\ ,c=3}$ ។

ខ-គណនាអាំងតេក្រាល $I=\int_0^1 f(x).dx$

$$f(x)=\frac{3x^2-7x+6}{(x-3)^2(x+1)}=\frac{4}{x+1}+\frac{2}{x-3}+\frac{3}{(x-3)^2}$$

គេបាន $I=\int_0^1\left[\frac{4}{x+1}+\frac{2}{x-3}+\frac{3}{(x-3)^2}\right].dx$

$$=\left[4\ln|x+1|+2\ln|x-3|-\frac{3}{x-3}\right]_0^1$$

$$=\left[4\ln 2+2\ln 2+\frac{3}{2}\right]-\left[4\ln 1+2\ln 3+1\right]$$

$$=6\ln 2+\frac{3}{2}-2\ln 3-1=\frac{1}{2}+2\ln\frac{8}{3}$$

ដូចនេះ $I=\int_0^1 f(x).dx=\frac{1}{2}+2\ln\frac{8}{3}$ ។

## លំហាត់ទី២៦

គេឱ្យអនុគមន៍ $f(x)$ កំនត់ និង មានដេរីវេត្រង់ចំនុច $x=c$ ។

ចូរស្រាយបញ្ជាក់ថា $\lim\limits_{h\to 0}\dfrac{f^2(c+h)-f^2(c-h)}{h}=4f'(c).f(c)$

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $\lim\limits_{h\to 0}\dfrac{f^2(c+h)-f^2(c-h)}{h}=4f'(c).f(c)$

តាង $L=\lim\limits_{h\to 0}\dfrac{f^2(c+h)-f^2(c-h)}{h}$

$$=\lim_{h\to 0}\frac{[f(c+h)-f(c-h)].[f(c+h)+f(c-h)]}{h}$$

$$=\lim_{h\to 0}\frac{f(c+h)-f(c-h)}{h}\times\lim_{h\to 0}[f(c+h)+f(c-h)]$$

$$\lim_{h\to 0}\frac{f(c+h)-f(c-h)}{h}=\lim_{h\to 0}\frac{[f(c+h)-f(c)]-[f(c-h)-f(c)]}{h}$$

$$=\lim_{h\to 0}\frac{f(c+h)-f(c)}{h}-\lim_{h\to 0}\frac{f(c-h)-f(c)}{h}$$

$$=\lim_{h\to 0}\frac{f(c+h)-f(c)}{h}+\lim_{h\to 0}\frac{f(c+(-h))-f(c)}{(-h)}$$

$$=f'(c)+f'(c)=2f'(c)$$

និង $\lim\limits_{h\to 0}[f(c+h)+f(c-h)]=f(c)+f(c)=2f(c)$

នាំឱ្យ $L=2f'(c)\times 2f(c)=4f'(c).f(c)$ ។

ដូចនេះ $\boxed{\lim\limits_{h\to 0}\dfrac{f^2(c+h)-f^2(c-h)}{h}=4f'(c).f(c)}$ ។

**លំហាត់ទី២៧**

គេឱ្យអនុគមន៍ $f(x)=\dfrac{e^x}{ax+b}$ ដែល $a\neq 0, a, b\in IR$

ក-ចូរគណនាដេរីវេ $f'(x)$ និង $f''(x)$

ខ-កំនត់ចំនួនពិត a និង b ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអប្បបរមាស្មើ $e$ ចំពោះ $x=1$ ។

**ដំណោះស្រាយ**

ក-គណនាដេរីវេ $f'(x)$ និង $f''(x)$

គេបាន $f'(x)=\dfrac{(e^x)'(ax+b)-(ax+b)'e^x}{(ax+b)^2}$

$$=\frac{e^x(ax+b)-ae^x}{(ax+b)^2}=\frac{(ax+b-a).e^x}{(ax+b)^2}$$

ដូចនេះ $\boxed{f'(x)=\dfrac{(ax+b-a).e^x}{(ax+b)^2}}$ ។

និង $f''(x)=\dfrac{[(ax+b-a)e^x]'(ax+b)^2-[(ax+b)^2]'(ax+b-a)e^x}{(ax+b)^4}$

$$=\frac{[ae^x+e^x(ax+b-a)](ax+b)^2-2a(ax+b)(ax+b-a)e^x}{(ax+b)^4}$$

$$=\frac{(ax+b)^2.e^x-2a(ax+b-a)e^x}{(ax+b)^3}=\frac{\left[(ax+b)^2-2a(ax+b-a)\right].e^x}{(ax+b)^3}$$

ដូចនេះ $\boxed{f''(x)=\dfrac{\left[(ax+b)^2-2a(ax+b-a)\right].e^x}{(ax+b)^3}}$ ។

ខ-កំនត់ចំនួនពិត a និង b

ដើម្បីឱ្យអនុគមន៍ $f(x)$ មានតម្លៃអប្បបរមាស្មើ $e$ ចំពោះ $x=1$ លុះត្រាតែ

$$\begin{cases} f'(1)=0 \\ f(1)=e \\ f''(1)>0 \end{cases}$$

បន្ទាប់ពីដោះស្រាយគេបាន $\boxed{a=1\ \ ,b=0}$

**លំហាត់ទី២៨**

គេឱ្យអនុគមន៍ f កំនត់លើ IR ដោយ $f(x)=\sin x$

ចូរបង្ហាញថាដេរីវេទី n នៃអនុគមន៍ f កំនត់ដោយ $f^{(n)}(x)=\sin(x+\frac{n\pi}{2})$

**ដំណោះស្រាយ**

បង្ហាញថាដេរីវេទី n នៃអនុគមន៍ f កំនត់ដោយ $f^{(n)}(x)=\sin(x+\frac{n\pi}{2})$

គេមាន $f(x)=\sin x$

គេបាន $f'(x)=\cos x=\sin(x+\frac{\pi}{2})$ ( ព្រោះ $\sin(\frac{\pi}{2}+\theta)=\sin\theta$ )

$$f''(x)=(x+\frac{\pi}{2})'\cos(x+\frac{\pi}{2})=\sin(x+\pi)$$

$$f'''(x)=(x+\pi)'\cos(x+\pi)=\sin(x+\frac{3\pi}{2})$$

..........................................................................

ឧបមាថាវាពិតដល់ដេរីវេលំដាប់ទី n គឺ $f^{(n)}(x) = \sin(x + \frac{n\pi}{2})$ ពិត

យើងនឹងស្រាយថាវាពិតដល់ដេរីវេលំដាប់ទី $(n+1)$ គឺ

$f^{(n+1)}(x) = \sin\left(x + \frac{(n+1)\pi}{2}\right)$ ពិត

យើងមាន $f^{(n+1)}(x) = (f^{(n)}(x))'$

ដោយ $f^{(n)}(x) = \sin(x + \frac{n\pi}{2})$

$$f^{(n+1)'}(x) = (x + \frac{n\pi}{2})'\cos(x + \frac{n\pi}{2})$$

$$= \sin(x + \frac{n\pi}{2} + \frac{\pi}{2}) = \sin\left(x + \frac{(n+1)\pi}{2}\right)$$

ដូចនេះ $\boxed{f^{(n)}(x) = \sin(x + \frac{n\pi}{2})}$ ។

## លំហាត់ទី២៩

គេមានអនុគមន៍ $f(x) = \frac{4x^2 - x + 1}{x^3 + 1}$ ដែល $x \neq -1$ ។

ក-កំនត់បីចំនួនពិត $a, b, c$ ដើម្បីឱ្យ $f(x) = \frac{a}{x+1} + \frac{bx + c}{x^2 - x + 1}$ ។

ខ-គណនាអាំងតេក្រាល $I = \int f(x).dx$ ។

## ដំណោះស្រាយ

ក-កំនត់ចំនួនពិត $a , b , c$

គេបាន $\frac{4x^2-x+1}{x^3+1}=\frac{a}{x+1}+\frac{bx+c}{x^2-x+1}$

$$\frac{4x^2-x+1}{(x+1)(x^2-x+1)}=\frac{a(x^2-x+1)+(x+1)(bx+c)}{(x+1)(x^2-x+1)}$$

$$4x^2-x+1=ax^2-ax+a+bx^2+cx+bx+c$$

$$4x^2-x+1=(a+b)x^2+(-a+b+c)x+(a+c)$$

គេទាញបាន $\begin{cases}a+b=4\\-a+b+c=-1\\a+c=1\end{cases}$ នាំឱ្យ $a=2\ ,\ b=2\ ,c=-1$ ។

ដូចនេះ $\boxed{a=2\ ,\ b=2\ ,c=-1}$ ។

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$

តាមសម្រាយខាងលើចំពោះ $a=2\ ,\ b=2\ ,c=-1$ គេមាន :

$$f(x)=\frac{4x^2-x+1}{x^3+1}=\frac{2}{x+1}+\frac{2x-1}{x^2-x+1}$$

គេបាន $I=\int(\ \frac{2}{x+1}+\frac{2x-1}{x^2-x+1}\ ).dx$

$$=\int\frac{2dx}{x+1}+\int\frac{(2x-1).dx}{x^2-x+1}$$

$$=2\int\frac{(x+1)'}{(x+1)}.dx+\int\frac{(x^2-x+1)'}{x^2-x+1}.dx$$

$$=2\ln|x+1|+\ln|x^2-x+1|+C$$

## លំហាត់ទី៣០

គេមានអនុគមន៍ $f(x)=\dfrac{5x^2-14x+13}{(x+1)(x-3)^2}$ ដែល $x\neq -1$ និង $x\neq 3$ ។

ក-កំនត់បីចំនួនពិត a , b , c ដើម្បីឱ្យ $f(x)=\dfrac{a}{x+1}+\dfrac{b}{x-3}+\dfrac{c}{(x-3)^2}$

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$ ។

## ដំណោះស្រាយ

ក-កំនត់ចំនួនពិត a , b , c

គេបាន $\dfrac{5x^2-14x+13}{(x+1)(x-3)^2}=\dfrac{a}{x+1}+\dfrac{b}{x-3}+\dfrac{c}{(x-3)^2}$

$$\frac{5x^2-14x+13}{(x+1)(x-3)^2}=\frac{a(x-3)^2+b(x+1)(x-3)+c(x+1)}{(x+1)(x-3)^2}$$

$$5x^2-14x+13=ax^2-6ax+9a+bx^2-2bx-3b+cx+c$$

$$5x^2-14x+13=(a+b)x^2+(-6a-2b+c)x+(9a-3b+c)$$

គេទាញបាន $\begin{cases} a+b=5 \\ -6a-2b+c=-14 \\ 9a-3b+c=13 \end{cases}$

នាំឱ្យ $a=2$ , $b=3$, $c=4$ ។

ដូចនេះ $\boxed{a=2\ ,\ b=3,\ c=4}$ ។

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$

តាមសម្រាយខាងលើចំពោះ $a=2$ , $b=3$ , $c=4$ គេមាន ៖

$$f(x)=\frac{5x^2-14x+13}{(x+1)(x-3)^2}=\frac{2}{x+1}+\frac{3}{x-3}+\frac{4}{(x-3)^2}$$

គេបាន $I=\int\left(\frac{2}{x+1}+\frac{3}{x-3}+\frac{4}{(x-3)^2}\right).dx$

$$=2\int\frac{dx}{x+1}+3\int\frac{dx}{x-3}+4\int\frac{dx}{(x-3)^2}$$

$$=2\ln|x+1|+3\ln|x-3|-\frac{4}{x-3}+c$$

## លំហាត់ទី៣១

គេឱ្យអនុគមន៍ $f(x)=\frac{1}{x(1+x^4)}$ ដែល x ជាចំនួនពិតខុសពីសូន្យ ។

ក-ចូរកំនត់បីចំនួនពិត A ,B និង C ដើម្បីឱ្យ $f(x)=\frac{A}{x}+\frac{Bx^3+C}{1+x^4}$

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$ ។

គ-ទាញរកអាំងតេក្រាល $J=\int\frac{4x^3\ln x.dx}{(1+x^4)^2}$

## ដំណោះស្រាយ

ក-កំនត់បីចំនួនពិត A , B , C

គេបាន $\frac{1}{x(1+x^4)}=\frac{A}{x}+\frac{Bx^3+C}{1+x^4}$

$$\frac{1}{x(1+x^4)} = \frac{A(1+x^4)+x(Bx^3+C)}{x(1+x^4)}$$

$$1 = A + Ax^4 + Bx^4 + Cx$$

$$1 = (A+B)\,x^4 + Cx + A$$

គេទាញ $\begin{cases} A+B=0 \\ C=0 \\ A=1 \end{cases}$ នាំឱ្យ $A=1$ , $B=-1$ , $C=0$ ។

ដូចនេះ $\boxed{A=1\ ,\ B=-1\ ,\ C=0}$ ។

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$

តាមសម្រាយខាងលើចំពោះ $A=1$ , $B=-1$ , $C=0$

គេមាន $f(x)=\frac{1}{x(1+x^4)}=\frac{1}{x}-\frac{x^3}{1+x^4}$

គេបាន $I=\int f(x).dx=\int\left(\frac{1}{x}-\frac{x^3}{1+x^4}\right).dx=\int\frac{dx}{x}-\frac{1}{4}\int\frac{4x^3dx}{1+x^4}$

ដូចនេះ $\boxed{I=\ln|x|-\frac{1}{4}\ln(1+x^4)+C}$ ។

គ-ទាញរកអាំងតេក្រាល $J=\int\frac{4x^3\ln x.dx}{(1+x^4)^2}$

តាង $\begin{cases} u=\ln x \\ dv=\frac{4x^3.dx}{(1+x^4)^2} \end{cases}$ នាំឱ្យ $\begin{cases} du=\frac{1}{x}.dx \\ v=\int\frac{4x^3.dx}{(1+x^4)^2}=-\frac{1}{1+x^4} \end{cases}$

គេបាន $J=-\frac{\ln x}{1+x^4}-\int(-\frac{1}{1+x^4}).\frac{1}{x}.dx$

$$=-\frac{\ln x}{1+x^4}+\int\frac{dx}{x(1+x^4)}=-\frac{\ln x}{1+x^4}+I$$

ដោយ $I=\ln|x|-\frac{1}{4}\ln(1+x^4)+C$

ដូចនេះ $\boxed{J=-\frac{\ln x}{1+x^4}+\ln|x|-\frac{1}{4}\ln(1+x^4)+C}$ ។

## លំហាត់ទី៣២

គេឱ្យអនុគមន៍ $f(x)=\frac{1}{e^{2x}+1}$ ដែល x ជាចំនួនពិត ។

ក-ចូរកំនត់បីចំនួនពិត A និង B ដើម្បីឱ្យ $f(x)=A+\frac{B.e^{2x}}{e^{2x}+1}$

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$ ។

គ-ទាញរកអាំងតេក្រាល $J=\int\frac{2xe^{2x}.dx}{(e^{2x}+1)^2}$

## ដំណោះស្រាយ

ក-កំនត់បីចំនួនពិត A , B

គេបាន $\frac{1}{e^{2x}+1}=A+\frac{B.e^{2x}}{e^{2x}+1}$

$$\frac{1}{e^{2x}+1}=\frac{A(e^{2x}+1)+B.e^{2x}}{e^{2x}+1}=\frac{(A+B)e^{2x}+A}{e^{2x}+1}$$

គេទាញ $\begin{cases} A+B=0 \\ A=1 \end{cases}$ នាំឱ្យ $A=1\ ,\ B=-1$ ។

ដូចនេះ $\boxed{A=1\ ,\ B=-1}$ ។

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$

តាមសម្រាយខាងលើចំពោះ $A=1\ ,\ B=-1$

គេមាន $f(x)=1-\dfrac{e^{2x}}{e^{2x}+1}$

គេបាន $I=\int (1-\dfrac{e^{2x}}{e^{2x}+1}).dx=\int dx-\dfrac{1}{2}\int \dfrac{2e^{2x}.dx}{e^{2x}+1}=x-\dfrac{1}{2}\ln(e^{2x}+1)+C$

ដូចនេះ $\boxed{I=x-\dfrac{1}{2}\ln(e^{2x}+1)+C}$ ។

គ-ទាញរកអាំងតេក្រាល $J=\int \dfrac{2xe^{2x}.dx}{(e^{2x}+1)^2}$

តាង $\begin{cases} u=x \\ dv=\dfrac{2e^{2x}.dx}{(e^{2x}+1)^2} \end{cases}$ នាំឱ្យ $\begin{cases} du=dx \\ v=\int \dfrac{2e^{2x}.dx}{(e^{2x}+1)^2}=-\dfrac{1}{e^{2x}+1} \end{cases}$

គេបាន $J=-\dfrac{x}{e^{2x}+1}+\int \dfrac{dx}{e^{2x}+1}=-\dfrac{x}{e^{2x}+1}+I$

ដោយ $I=x-\dfrac{1}{2}\ln(e^{2x}+1)+C$

ដូចនេះ $\boxed{J=-\dfrac{x}{e^{2x}+1}+x-\dfrac{1}{2}\ln(e^{2x}+1)+C}$ ។

## លំហាត់ទី៣៣

គេឱ្យអាំងតេក្រាល $I=\int e^{x}\cos^{2}x.dx$ និង $J=\int e^{x}\sin^{2}x.dx$

ក-ចូរគណនា $I+J$ និង $I-J$

ខ-ទាញរក $I$ និង $J$

## ដំណោះស្រាយ

ក-គណនា $I+J$ និង $I-J$

គេបាន $I+J=\int e^{x}\cos^{2}x.dx+\int e^{x}\sin^{2}x.dx$

$$=\int (e^{x}\cos^{2}x+e^{x}\sin^{2}x).dx=\int e^{x}.dx$$

ដូចនេះ $\boxed{I+J=e^{x}+C_1}$ ។

គេបាន $I-J=\int e^{x}\cos^{2}x.dx-\int e^{x}\sin^{2}x.dx$

$$=\int (e^{x}\cos^{2}x-e^{x}\sin^{2}x).dx=\int e^{x}(\cos^{2}x-\sin^{2}x).dx$$

$$=\int e^{x}\cos 2x.dx$$

តាង $\begin{cases} u=e^{x} \\ dv=\cos 2x.dx \end{cases}$ នាំឱ្យ $\begin{cases} du=e^{x}dx \\ v=\frac{1}{2}\sin 2x \end{cases}$

គេបាន $I-J=\frac{1}{2}e^{x}\sin 2x-\int \frac{1}{2}e^{x}\sin 2x.dx$

តាង $\begin{cases} u = \frac{1}{2}e^x \\ dv = \sin 2x.dx \end{cases}$ នាំឱ្យ $\begin{cases} du = \frac{1}{2}e^x.dx \\ v = -\frac{1}{2}\cos 2x \end{cases}$

គេបាន $I - J = \frac{1}{2}e^x \sin 2x - \left[ -\frac{1}{4}e^x \cos 2x + \frac{1}{4}\int e^x \cos 2x.dx \right]$

$$I - J = \frac{1}{2}e^x \sin 2x + \frac{1}{4}e^x \cos 2x - \frac{1}{4}\int e^x \cos 2x.dx$$

$$I - J = \frac{1}{2}(\sin 2x + \frac{1}{2}\cos 2x)e^x - \frac{1}{4}(I - J)$$

$$\frac{5}{4}(I - J) = \frac{1}{2}(\sin 2x + \frac{1}{2}\cos 2x)e^x$$

ដូចនេះ $\boxed{I - J = \frac{2}{5}(\sin 2x + \frac{1}{2}\cos 2x)e^x + C_2}$ ។

ខ-ទាញរក I និង J

តាមសម្រាយខាងលើគេមាន $\begin{cases} I + J = e^x + C_1 \\ I - J = \frac{2}{5}(\sin 2x + \frac{1}{2}\cos 2x)e^x + C_2 \end{cases}$

បន្ទាប់ពីដោះស្រាយប្រព័ន្ធសមីការខាងលើនេះគេបាន :

$$I = \frac{1}{2}(1 + \frac{2}{5}\sin 2x + \frac{1}{5}\cos 2x)e^x + K_1$$

និង $J = \frac{1}{2}(1 - \frac{2}{5}\sin 2x - \frac{1}{5}\cos 2x)e^x + K_2$ ។

## លំហាត់ទី៣៤

គេឱ្យអាំងតេក្រាល :

$$I=\int \frac{1+\cos x}{2+\sin x+\cos x}.dx \text{ និង } J=\int \frac{1+\sin x}{2+\sin x+\cos x}.dx$$

ក-គណនា $I+J$ និង $I-J$

ខ-ទាញរក $I$ និង $J$

## ដំណោះស្រាយ

ក-គណនា $I+J$ និង $I-J$

គេបាន $I+J=\int \frac{1+\cos x}{2+\sin x+\cos x}.dx+\int \frac{1+\sin x}{2+\sin x+\cos x}.dx$

$$=\int (\frac{1+\cos x}{2+\sin x+\cos x}+\frac{1+\sin x}{2+\sin x+\cos x}).dx$$

$$=\int \frac{2+\cos x+\sin x}{2+\sin x+\cos x}.dx=\int dx=x+C_1$$

ដូចនេះ $\boxed{I+J=x+C_1}$ ។

គេបាន $I-J=\int \frac{1+\cos x}{2+\sin x+\cos x}.dx-\int \frac{1+\sin x}{2+\sin x+\cos x}.dx$

$$=\int (\frac{1+\cos x}{2+\sin x+\cos x}-\frac{1+\sin x}{2+\sin x+\cos x}).dx$$

$$=\int \frac{\cos x-\sin x}{2+\sin x+\cos x}.dx=\int \frac{(2+\sin x+\cos x)'}{2+\sin x+\cos x}dx$$

$$=\ln|2+\sin x+\cos x|+C_2$$

ដូចនេះ $\boxed{I - J = \ln|2+\sin x+\cos x| + C_2}$ ។

ខ-គណនាអាំងតេក្រាល I និង J

គេមាន $\begin{cases} I + J = x + C_1 & (1) \\ I - J = \ln|2+\sin x+\cos x| + C_2 & (2) \end{cases}$

បូកសមីការ (1) និង (2) គេបាន :

$$2I = x + \ln|2+\sin x+\cos x| + C_1 + C_2$$

ដូចនេះ $\boxed{I = \frac{x}{2} + \frac{1}{2}\ln|2+\sin x+\cos x| + K_1}$ ដែល $K_1 = \frac{C_1 + C_2}{2}$

ដកសមីការ (1) និង (2) គេបាន :

$$2J = x - \ln|2+\sin x+\cos x| + C_1 - C_2$$

ដូចនេះ $\boxed{I = \frac{x}{2} - \frac{1}{2}\ln|2+\sin x+\cos x| + K_2}$ ដែល $K_2 = \frac{C_1 - C_2}{2}$

## លំហាត់ទី៣៥

គេឲ្យអាំងតេក្រាល $I_0 = \int_0^1 \frac{dt}{1+t+t^2}$

និង $I_n = \int_0^1 \frac{t^n}{1+t+t^2}.dt \quad , \ ( n \in IN )$

ក-ចូរគណនាតម្លៃនៃ $I_0$ រួច ស្រាយថា $(I_n)$ជាស្វ៊ីតចុះ។

ខ-ស្រាយបញ្ជាក់ថា $I_n + I_{n+1} + I_{n+2} = \frac{1}{n+1}$ ។

គ_ទាញឲ្យបានថា $\frac{1}{3(n+1)} \le I_n \le \frac{1}{3(n-1)}$ , $\forall n \ge 2$ ។

ទាញរកលីមីត $\lim_{n\to+\infty}(n I_n)$ ។

**ដំណោះស្រាយ**

ក. គណនាតម្លៃនៃ $I_0$ រួច ស្រាយថា $(I_n)$ ជាស៊ីតចុះ

យើងបាន $I_0 = \int_0^1 \frac{dt}{1+t+t^2} = \int_0^1 \frac{dt}{\frac{3}{4}+(\frac{1}{2}+t)^2}$

តាង $U = \frac{1}{2}+t$ នាំឱ្យ $dU = dt$

ហើយចំពោះ $\forall t \in [0,1]$ នោះ $U \in \left[\frac{1}{2},\frac{3}{2}\right]$

គេបាន $I_0 = \int_{\frac{1}{2}}^{\frac{3}{2}} \frac{dU}{(\frac{\sqrt{3}}{2})^2+U^2} = \left[\frac{2}{\sqrt{3}}\arctan\left(\frac{2U}{\sqrt{3}}\right)\right]_{\frac{1}{2}}^{\frac{3}{2}}$

$$= \frac{2}{\sqrt{3}}\arctan\sqrt{3} - \frac{2}{\sqrt{3}}\arctan\frac{1}{\sqrt{3}}$$

$$= \frac{2}{\sqrt{3}}\left(\frac{\pi}{3}-\frac{\pi}{6}\right) = \frac{\pi}{3\sqrt{3}}$$

ដូចនេះ $I_0 = \int_0^1 \frac{dt}{1+t+t^2} = \frac{\pi}{3\sqrt{3}}$ ។

ម្យ៉ាងទៀតគេមាន $I_n = \int_0^1 \frac{t^n}{1+t+t^2}.dt$ និង $I_{n+1} = \int_0^1 \frac{t^{n+1}}{1+t+t^2}.dt$

ចំពោះគ្រប់ $t \in [0,1]$ គេមាន $t^{n+1} \le t^n$ នាំឱ្យ $\frac{t^{n+1}}{1+t+t^2} \le \frac{t^n}{1+t+t^2}$

គេទាញ $\int_0^1 \frac{t^{n+1}}{1+t+t^2}.dt \le \int_0^1 \frac{t^n}{1+t+t^2}.dt$ ឬ $I_{n+1} \le I_n \ , \forall n \in IN$

ដូចនេះ $(I_n)$ ជាស្វ៊ីតចុះ ។

ខ. ស្រាយបញ្ជាក់ថា $I_n + I_{n+1} + I_{n+2} = \frac{1}{n+1}$

យើងបាន $I_n + I_{n+1} + I_{n+2} = \int_0^1 \frac{t^n dt}{1+t+t^2} + \int_0^1 \frac{t^{n+1}dt}{1+t+t^2} + \int_0^1 \frac{t^{n+2}dt}{1+t+t^2}$

$$= \int_0^1 \frac{(t^n + t^{n+1} + t^{n+2})dt}{1+t+t^2} = \int_0^1 \frac{t^n(1+t+t^2).dt}{1+t+t^2}$$

$$= \int_0^1 t^n dt = \left[\frac{1}{n+1}t^{n+1}\right]_0^1 = \frac{1}{n+1}$$

ដូចនេះ $I_n + I_{n+1} + I_{n+2} = \frac{1}{n+1}$ ។

គ. ទាញឱ្យបានថា $\frac{1}{3(n+1)} \le I_n \le \frac{1}{3(n-1)} \ , \forall n \ge 2$

យើងមាន $(I_n)$ ជាស្វ៊ីតចុះ ។ តាមលក្ខណៈនៃស្វ៊ីតចុះយើងមាន :

$$I_n + I_{n+1} + I_{n+2} \le 3I_n \le I_{n-2} + I_{n-1} + I_n$$

ដោយ $I_n + I_{n+1} + I_{n+2} = \frac{1}{n+1}$ នាំឱ្យ $I_{n-2} + I_{n-1} + I_n = \frac{1}{n-1}$

គេទាញ $\frac{1}{n+1} \le 3I_n \le \frac{1}{n-1}$

នាំឱ្យ $\frac{1}{3(n+1)} \le I_n \le \frac{1}{3(n-1)}$ , $\forall n \ge 2$ ។

ទាញរកលីមីត $\lim_{n\to+\infty}(n I_n)$

មាន $\frac{1}{3(n+1)} \le I_n \le \frac{1}{3(n-1)}$ , $\forall n \ge 2$

នាំឱ្យ $\frac{n}{3(n+1)} \le nI_n \le \frac{n}{3(n-1)}$

ដូចនេះ $\lim_{n\to+\infty}\left(nI_n\right) = \frac{1}{3}$ ។

## លំហាត់ទី៣៦

គេឱ្យអាំងតេក្រាល $I=\int x\cos^2 x.dx$ និង $J=\int x\sin^2 x.dx$

ក-ចូរគណនា $I+J$ និង $I-J$

ខ-ទាញរក $I$ និង $J$

## ដំណោះស្រាយ

ក-គណនា $I+J$ និង $I-J$

គេបាន $I+J=\int x\cos^2 x.dx+\int x\sin^2 x.dx$

$$=\int (x\cos^2 x+x\sin^2 x).dx=\int x(\cos^2 x+\sin^2 x).dx=\int x.dx$$

ដូចនេះ $\boxed{I+J=\frac{1}{2}x^2+C_1}$ ។

គេបាន $I-J=\int x\cos^2 x.dx-\int x\sin^2 x.dx$

$$=\int (x\cos^2 x-x\sin^2 x).dx=\int x(\cos^2 x-\sin^2 x).dx$$

$$=\int x\cos 2x.dx$$

តាង $\begin{cases} u=x \\ dv=\cos 2x.dx \end{cases}$ នាំឱ្យ $\begin{cases} du=dx \\ v=\frac{1}{2}\sin 2x \end{cases}$

គេបាន $I-J=\frac{1}{2}x\sin 2x-\int \frac{1}{2}\sin 2x.dx$

ដូចនេះ $I - J = \frac{1}{2}x\sin 2x + \frac{1}{4}\cos 2x + C$ ។

ខ-ទាញរក $I$ និង $J$

តាមសម្រាយខាងលើគេមាន $\begin{cases} I + J = \frac{1}{2}x^2 + C_1 \\ I - J = \frac{1}{2}x\sin 2x + \frac{1}{4}\cos 2x + C_2 \end{cases}$

បន្ទាប់ពីដោះស្រាយប្រព័ន្ធសមីការខាងលើនេះគេបាន :

$$I = \frac{1}{2}(\frac{1}{2}x^2 + \frac{1}{2}x\sin 2x + \frac{1}{4}\cos 2x) + K_1$$

និង $J = \frac{1}{2}(\frac{1}{2}x^2 - \frac{1}{2}x\sin 2x - \frac{1}{4}\cos 2x) + K_2$ ។

## លំហាត់ទី៣៧

គេមានអនុគមន៍ $f(x) = \frac{6x^2 - 22x + 18}{(x-1)(x-2)(x-3)}$ ដែល $x \neq \{1, 2, 3\}$ ។

ក-កំនត់បីចំនួនពិត $a, b, c$ ដើម្បីឱ្យ $f(x) = \frac{a}{x-1} + \frac{b}{x-2} + \frac{c}{x-3}$ ។

ខ-គណនាអាំងតេក្រាល $I = \int f(x).dx$ ។

## ដំណោះស្រាយ

ក- កំនត់បីចំនួនពិត $a, b, c$

គេបាន $\frac{6x^2 - 22x + 18}{(x-1)(x-2)(x-3)} = \frac{a}{x-1} + \frac{b}{x-2} + \frac{c}{x-3}$

$$\frac{6x^2-22x+18}{(x-1)(x-2)(x-3)}=\frac{a(x-2)(x-3)+b(x-1)(x-3)+c(x-1)(x-2)}{(x-1)(x-2)(x-3)}$$

$$6x^2-22x+18=a(x-2)(x-3)+b(x-1)(x-3)+c(x-1)(x-2)$$

-ចំពោះ $x=1$ គេបាន $2=2a$ នាំឱ្យ $a=1$

-ចំពោះ $x=2$ គេបាន $-2=-b$ នាំឱ្យ $b=2$

-ចំពោះ $x=3$ គេបាន $6=2c$ នាំឱ្យ $c=3$

ដូចនេះ $\boxed{a=1\ ,\ b=2\ ,\ c=3}$ ។

ខ-គណនាអាំងតេក្រាល $I=\int f(x).dx$

ចំពោះ $a=1, b=2\ , c=3$

គេមាន $f(x)=\frac{1}{x-1}+\frac{2}{x-2}+\frac{3}{x-3}$

គេបាន $I=\int(\frac{1}{x-1}+\frac{2}{x-2}+\frac{3}{x-3}).dx$

$$=\int\frac{dx}{x-1}+2\int\frac{dx}{x-2}+3\int\frac{dx}{x-3}$$

$$=\ln|x-1|+2\ln|x-2|+3\ln|x-3|+C$$

ដូចនេះ $\boxed{I=\int f(x).dx=\ln|x-1|+2\ln|x-2|+3\ln|x-3|+C}$

## លំហាត់ទី៣៨

គេមានអាំងតេក្រាល $I=\int_0^{\frac{\pi}{4}}\cos^2 x.dx$ និង $J=\int_0^{\frac{\pi}{4}}\sin^2 x.dx$

ក-ចូរគណនា $I+J$ និង $I-J$ ។

ខ-ទាញរកតម្លៃនៃ $I$ និង $J$ ។

## ដំណោះស្រាយ

ក-គណនា $I+J$ និង $I-J$

យើងបាន $I+J=\int_0^{\frac{\pi}{4}}\cos^2 x.dx+\int_0^{\frac{\pi}{4}}\sin^2 x.dx$

$$=\int_0^{\frac{\pi}{4}}(\cos^2 x+\sin^2 x).dx=\int_0^{\frac{\pi}{4}}dx=\frac{\pi}{4}$$

ដូចនេះ $\boxed{I+J=\frac{\pi}{4}}$ ។

យើងបាន $I-J=\int_0^{\frac{\pi}{4}}\cos^2 x.dx-\int_0^{\frac{\pi}{4}}\sin^2 x.dx$

$$=\int_0^{\frac{\pi}{4}}(\cos^2 x-\sin^2 x).dx=\int_0^{\frac{\pi}{4}}\cos 2xdx$$

$$=\left[\frac{1}{2}\sin 2x\right]_0^{\frac{\pi}{4}}=\frac{1}{2}\sin\frac{\pi}{2}-\frac{1}{2}\sin 0=\frac{1}{2}$$

ដូចនេះ $\boxed{I - J = \frac{1}{2}}$ ។

ខ-ទាញរកតម្លៃនៃ I និង J

គេមាន $\begin{cases} I + J = \frac{\pi}{4} \\ I - J = \frac{1}{2} \end{cases}$ នាំឱ្យ $I = \frac{\pi}{8} + \frac{1}{4}$ និង $J = \frac{\pi}{8} - \frac{1}{4}$ ។

## លំហាត់ទី៣៩

គេមានអនុគមន៍ $f(x) = \frac{2x+1}{x(x+1)}$ ដែល $x \neq -1$ និង $x \neq 0$ ។

ក-កំនត់បីចំនួនពិត A និង B ដើម្បីឱ្យ $f(x) = \frac{A}{x} + \frac{B}{x+1}$ ។

ខ-គណនាអាំងតេក្រាល $I = \int_1^3 f(x).dx$ ។

## ដំណោះស្រាយ

ក- កំនត់បីចំនួនពិត A និង B

គេបាន $\frac{2x+1}{x(x+1)} = \frac{A}{x} + \frac{B}{x+1}$ នាំឱ្យ $2x + 1 = A(x+1) + Bx$

-ចំពោះ $x = 0$ នាំឱ្យ $1 = A$ ឬ $A = 1$

-ចំពោះ $x = -1$ នាំឱ្យ $-1 = -B$ ឬ $B = 1$

ដូចនេះ $\boxed{A = 1 \,,\; B = 1}$ ។

ខ-គណនាអាំងតេក្រាល $I=\int_1^3 f(x).dx$

ចំពោះ $A=1$ , $B=1$ គេមាន $f(x)=\frac{1}{x}+\frac{1}{x+1}$

គេបាន $I=\int_1^3(\frac{1}{x}+\frac{1}{x+1}).dx=[\ln|x|+\ln|x+1)]_1^3=(\ln 3+\ln 4)-(\ln 1+\ln 2)$

ដូចនេះ $\boxed{I=\ln 12-\ln 2=\ln 6}$ ។

## លំហាត់ទី៤០

គេមានអាំងតេក្រាល $I=\int_{\frac{\pi}{4}}^{\frac{\pi}{2}}\frac{dx}{\sin x}$ និង $J=\int_{\frac{\pi}{4}}^{\frac{\pi}{2}}\frac{dx}{\sin^3 x}$

ក-កំនត់ពីរចំនួនពិត a, b ដើម្បីឱ្យ $\frac{1}{\sin x}=\frac{a\sin x}{1+\cos x}+\frac{b\sin x}{1-\cos x}$ ។

ខ-គណនាអាំងតេក្រាល I រួចទាញរកតម្លៃ J ។

## ដំណោះស្រាយ

ក- កំនត់បីចំនួនពិត a, b

យើងបាន $\frac{1}{\sin x}=\frac{a\sin x}{1+\cos x}+\frac{b\sin x}{1-\cos x}$

$$\frac{1}{\sin x} = \frac{a\sin x(1-\cos x) + b\sin x(1+\cos x)}{1-\cos^2 x}$$

$$\frac{1}{\sin x} = \frac{\sin x(a - a\cos x + b + b\cos x)}{\sin^2 x}$$

$$\frac{1}{\sin x} = \frac{(a+b)-(a-b)\cos x}{\sin x}$$

គេទាញបាន $\begin{cases} a+b=1 \\ a-b=0 \end{cases}$ នាំឱ្យ $a=b=\frac{1}{2}$

ដូចនេះ $\boxed{a=\frac{1}{2}\ ,\ b=\frac{1}{2}}$ ។

ខ-គណនាអាំងតេក្រាល I រួចទាញរកតម្លៃ J

ចំពោះ $a=\frac{1}{2}\ ,\ b=\frac{1}{2}$

គេមាន $\frac{1}{\sin x} = \frac{1}{2}\frac{\sin x}{1-\cos x} + \frac{1}{2}\frac{\sin x}{1+\cos x}$

គេបាន $I = \int_{\frac{\pi}{4}}^{\frac{\pi}{2}} \left(\frac{1}{2}\frac{\sin x}{1-\cos x} + \frac{1}{2}\frac{\sin x}{1+\cos x}\right).dx$

$$= \frac{1}{2}\int_{\frac{\pi}{4}}^{\frac{\pi}{2}} \frac{\sin x}{1-\cos x}.dx + \frac{1}{2}\int_{\frac{\pi}{4}}^{\frac{\pi}{2}} \frac{\sin x}{1+\cos x}.dx$$

$$I=\frac{1}{2}\int_{\frac{\pi}{4}}^{\frac{\pi}{2}}\frac{(1-\cos x)'}{(1-\cos x)}.dx-\frac{1}{2}\int_{\frac{\pi}{4}}^{\frac{\pi}{2}}\frac{(1+\cos x)'}{(1+\cos x)}.dx$$

$$=\frac{1}{2}\left[\ln|1-\cos x|\right]_{\frac{\pi}{4}}^{\frac{\pi}{2}}-\frac{1}{2}\left[\ln|1+\cos x|\right]_{\frac{\pi}{4}}^{\frac{\pi}{2}}$$

$$=\frac{1}{2}\left[\ln 1-\ln(1-\frac{1}{\sqrt{2}})\right]-\frac{1}{2}\left[\ln 1-\ln(1+\frac{1}{\sqrt{2}})\right]$$

$$=\frac{1}{2}\left[-\ln(\frac{\sqrt{2}-1}{\sqrt{2}})+\ln(\frac{\sqrt{2}+1}{\sqrt{2}})\right]$$

$$=\frac{1}{2}\ln(\frac{\sqrt{2}+1}{\sqrt{2}-1})=\ln(\sqrt{2}+1)$$

ដូចនេះ $\boxed{I=\ln(1+\sqrt{2})}$ ។

ម្យ៉ាងទៀត $J=\int_{\frac{\pi}{4}}^{\frac{\pi}{2}}\frac{dx}{\sin^3 x}=\int_{\frac{\pi}{4}}^{\frac{\pi}{2}}\frac{1}{\sin x}.\frac{dx}{\sin^2 x}$

តាង $\begin{cases}u=\frac{1}{\sin x}\\ dv=\frac{dx}{\sin^2 x}\end{cases}$ នាំឱ្យ $\begin{cases}du=-\frac{\cos x}{\sin^2 x}\\ v=\int\frac{dx}{\sin^2 x}=-\cot x=-\frac{\cos x}{\sin x}\end{cases}$

គេបាន $J = \left[ -\frac{\cos x}{\sin^2 x} \right]_{\frac{\pi}{4}}^{\frac{\pi}{2}} - \int_{\frac{\pi}{4}}^{\frac{\pi}{2}} \frac{\cos^2 x}{\sin^3 x}.dx$

$$J = \sqrt{2} - \int_{\frac{\pi}{4}}^{\frac{\pi}{2}} \frac{1 - \sin^2 x}{\sin^3 x}.dx = \sqrt{2} - \int_{\frac{\pi}{4}}^{\frac{\pi}{2}} \frac{dx}{\sin^3 x} + \int_{\frac{\pi}{4}}^{\frac{\pi}{2}} \frac{dx}{\sin x}$$

$J = \sqrt{2} - J + I$ នាំឱ្យ $J = \frac{\sqrt{2}}{2} + \frac{I}{2}$ ដោយ $I = \ln(1 + \sqrt{2})$

ដូចនេះ $\boxed{J = \frac{\sqrt{2}}{2} + \frac{1}{2}\ln(1 + \sqrt{2})}$ ។

## លំហាត់ទី៤១

គេមានអនុគមន៍ $f(x) = \frac{e^{4x} + 1}{(e^{2x} + 1)^2}$ ដែល $x$ ជាចំនួនពិត ។

ក-កំនត់បីចំនួនពិត $A$ , $B$ ដើម្បីឱ្យ $f(x) = A + \frac{B.e^{2x}}{(e^{2x} + 1)^2}$ ។

ខ-គណនាអាំងតេក្រាល $I = \int_0^{\frac{1}{2}} f(x).dx$ ។

## ដំណោះស្រាយ

ក- កំនត់បីចំនួនពិត $A , B$

គេមាន $f(x) = \frac{e^{4x} + 1}{(e^{2x} + 1)^2} = \frac{(e^{4x} + 2e^{2x} + 1) - 2e^{2x}}{(e^{2x} + 1)^2} = \frac{(e^{2x} + 1)^2 - 2e^{2x}}{(e^{2x} + 1)^2}$

$$f(x)=1-\frac{2e^{2x}}{(e^{2x}+1)^2}=A+\frac{Be^{2x}}{(e^{2x}+1)^2}$$

ដូចនេះ $\boxed{A=1\ ,\ B=-2}$ ។

ខ-គណនាអាំងតេក្រាល $I=\int_0^{\frac{1}{2}} f(x).dx$

គេមាន $f(x)=1-\frac{2e^{2x}}{(e^{2x}+1)^2}$

គេបាន $I=\int_0^{\frac{1}{2}}[1-\frac{2e^{2x}}{(e^{2x}+1)^2}].dx$

$$=\int_0^{\frac{1}{2}}dx-\int_0^{\frac{1}{2}}\frac{(e^{2x}+1)'}{(e^{2x}+1)^2}.dx$$

$$=\frac{1}{2}-\left[-\frac{1}{e^{2x}+1}\right]_0^{\frac{1}{2}}=\frac{1}{2}+\left[\frac{1}{e+1}-\frac{1}{2}\right]=\frac{1}{e+1}$$

ដូចនេះ $\boxed{I=\frac{1}{e+1}}$ ។

## លំហាត់ទី៤២

គេឱ្យអនុគមន៍ $f(x)=\dfrac{2x^2+4x+3}{(x+1)(x+2)^2}$ ។

ក-កំនត់បីចំនួនពិត $A, B$ និង $C$ ដើម្បីឱ្យអនុគមន៍ $f(x)$ អាចសរសេរជារាង

$$f(x)=\frac{A}{x+1}+\frac{B}{x+2}+\frac{C}{(x+2)^2}$$ ។

ខ-គណនាអាំងតេក្រាល $I=\int_0^1 f(x).dx$ ។

## ដំណោះស្រាយ

ក-កំនត់បីចំនួនពិត $A, B$ និង $C$

គេមាន $f(x)=\dfrac{2x^2+4x+3}{(x+1)(x+2)^2}$ និង $f(x)=\dfrac{A}{x+1}+\dfrac{B}{x+2}+\dfrac{C}{(x+2)^2}$

គេបាន $\dfrac{2x^2+4x+3}{(x+1)(x+2)^2}=\dfrac{A}{x+1}+\dfrac{B}{x+2}+\dfrac{C}{(x+2)^2}$

$$\frac{2x^2+4x+3}{(x+1)(x+2)^2}=\frac{A.(x+2)^2+B.(x+1)(x+2)+C.(x+1)}{(x+1)(x+2)^2}$$

$$2x^2+4x+3=A.(x+2)^2+B.(x+1)(x+2)+C.(x+1) \quad (1)$$

ចំពោះ $x=-1$ តាម $(1)$ គេបាន $2-4+3=A$ នាំឱ្យ $A=1$

ចំពោះ $x=-2$ តាម $(1)$ គេបាន $8-8+3=-C$ នាំឱ្យ $C=-3$

ចំពោះ $x=0$ តាម $(1)$ គេបាន $3=4A+2B+C$

នាំឱ្យ $B = \frac{3-4A-C}{2} = \frac{3-4+3}{2} = 1$ ។

ដូចនេះ $\boxed{A = 1\ \ ,B = 1\ \ ,C = -3}$ ។

ខ-គណនាអាំងតេក្រាល $I = \int_0^1 f(x).dx$

ចំពោះ $A = 1, B = 1, C = -3$ គេបាន $f(x) = \frac{1}{x+1} + \frac{1}{x+2} - \frac{3}{(x+2)^2}$

គេបាន $I = \int_0^1 f(x).dx = \int_0^1 \left[\frac{1}{x+1} + \frac{1}{x+2} - \frac{3}{(x+2)^2}\right].dx$

$$I = \int_0^1 \frac{1}{x+1}.dx + \int_0^1 \frac{1}{x+2}.dx - 3\int_0^1 \frac{1}{(x+2)^2}.dx$$

$$I = \int_0^1 \frac{(x+1)'}{(x+1)}.dx + \int_0^1 \frac{(x+2)'}{(x+2)}.dx - 3.\int_0^1 \frac{(x+2)'}{(x+2)^2}.dx$$

$$I = \left[\ln|x+1|\right]_0^1 + \left[\ln|x+2|\right]_0^1 - 3.\left[-\frac{1}{x+2}\right]_0^1$$

$$I = \left[\ln 2 - \ln 1\right] + \left[\ln 3 - \ln 2\right] + 3\left[\frac{1}{3} - \frac{1}{2}\right]$$

$$I = \ln 2 - 0 + \ln 3 - \ln 2 + 1 - \frac{3}{2}$$

$$I = \ln 3 - \frac{1}{2} = \frac{-1+2\ln 3}{2}$$

ដូចនេះ $\boxed{I = \int_0^1 f(x).dx = \frac{-1+2\ln 3}{2}}$ ។

## លំហាត់ទី៤៣

គេឱ្យអនុគមន៍ $f(x)=\dfrac{e^x-1}{e^x+1}$ កំនត់លើ IR ។

ក-ចូរសរសេរ $f(x)$ ជារាង $f(x)=A+\dfrac{B.e^{-x}}{1+e^{-x}}$

ខ-គណនាអាំងតេក្រាល $I=\int_0^1 f(x).dx$

ដោយសរសេរលទ្ធផលជារាង $a+\ln b$ ដែល a និង b ជាពីរចំនួនពិតត្រូវរក

## ដំណោះស្រាយ

ក- សរសេរ $f(x)$ ជារាង $f(x)=A+\dfrac{B.e^{-x}}{1+e^{-x}}$

$$f(x)=\frac{e^x-1}{e^x+1}=\frac{(e^x+1)-2}{e^x+1}=1-\frac{2}{e^x+1}$$

$$=1-\frac{2e^{-x}}{e^{-x}(e^x+1)}=1-\frac{2e^{-x}}{1+e^{-x}}$$

ដូចនេះ $f(x)=1+\dfrac{-2e^{-x}}{1+e^{-x}}$ ហើយ $A=1$ និង $B=-2$ ។

ខ-គណនាអាំងតេក្រាល $I=\int_0^1 f(x).dx$

គេបាន $I=\int_0^1\left(1+\dfrac{-2e^{-x}}{1+e^{-x}}\right).dx$ ព្រោះ $f(x)=1+\dfrac{-2e^{-x}}{1+e^{-x}}$

$$=\int_0^1\left[1+2.\frac{(1+e^{-x})'}{\left(1+e^{-x}\right)}\right].dx=\left[x+2\ln\left(1+e^{-x}\right)\right]_0^1$$

$$=\left[1+2\ln\left(1+e^{-1}\right)\right]-\left[0+2\ln(1+1)\right]=1+2\ln\left(\frac{e+1}{e}\right)-2\ln 2$$

$$=1+2\ln(e+1)-2\ln e-2\ln 2$$

$$=1+2[\ln(e+1)-\ln 2]-2=-1+2\ln\left(\frac{e+1}{2}\right)$$

ដូចនេះ $I=\int_0^1 f(x).dx=-1+2\ln\left(\frac{e+1}{2}\right)$

ហើយ $a=-1$ និង $b=\frac{e+1}{2}$ ។

## លំហាត់ទី៤៤

គេឱ្យអនុគមន៍ $f(x)=\left(x^2+x-7\right).e^x$ កំនត់លើ IR ។

ក-កំនត់ចំនួនពិត $a,b$ និង $c$ ដើម្បីឱ្យអនុគមន៍ $F(x)=\left(ax^2+bx+c\right).e^x$

ជាព្រីមីទីវនៃអនុគមន៍ $f(x)$ ។

ខ-គណនាអាំងតេក្រាល $I=\int_0^3 f(x).dx$

## ដំណោះស្រាយ

ក-កំនត់ចំនួនពិត $a,b$ និង $c$

ដើម្បីឱ្យអនុគមន៍ $F(x)$ ជាព្រីមីទីវនៃអនុគមន៍ $f(x)$ លុះត្រាតែ :

$\forall x \in IR : F'(x) = f(x)$

គេបាន $F'(x) = (ax^2 + bx + c)'.e^x + (e^x)'.(ax^2 + bx + c)$

$= (2ax + b).e^x + e^x(ax^2 + bx + c)$

$= [ax^2 + (2a + b)x + (b + c)].e^x$

ដោយ $F'(x) = f(x)$

នាំឱ្យ $[ax^2 + (2a + b)x + (b + c)].e^x = (x^2 + x - 7).e^x$

គេទាញបាន $\begin{cases} a = 1 \\ 2a + b = 1 \\ b + c = -7 \end{cases}$ នាំឱ្យ $\begin{cases} a = 1 \\ b = -1 \\ c = -6 \end{cases}$ ។

ដូចនេះ $\boxed{a = 1 \ , b = -1 \ , c = -6}$ ។

ខ-គណនាអាំងតេក្រាល $I = \int_0^3 f(x).dx$

ដោយ $F(x)$ ជាព្រីមីទីវនៃអនុគមន៍ $f(x)$ នោះគេបាន :

$I = \int_0^3 f(x).dx = [F(x)]_0^3 = F(3) - F(0)$

ចំពោះ $a = 1, b = -1, c = -6$ គេមាន $F(x) = (x^2 - x - 6).e^x$

គេបាន $F(3) = (9 - 3 - 6).e^3 = 0$ និង $F(0) = (0 - 0 - 6).e^0 = -6$

ដូចនេះ $I = 0 - (-6) = 6$ ។

## លំហាត់ទី៤៥

គេឱ្យអនុគមន៍ $f(x)=\frac{1}{x^2-1}$

ក-កំនត់ចំនួនពិត A និង B ដើម្បីឱ្យ $f(x)=\frac{A}{x-1}+\frac{B}{x+1}$

ខ-គណនាអាំងតេក្រាល $I=\int_2^5 f(x).dx$ ។

## ដំណោះស្រាយ

ក-កំនត់ចំនួនពិត a និង b

គេបាន $\frac{1}{x^2-1}=\frac{A}{x-1}+\frac{B}{x+1}$

$$\frac{1}{(x-1)(x+1)}=\frac{A.(x+1)+B.(x-1)}{(x-1)(x+1)}$$

$$1=A.(x+1)+B.(x-1)$$

$$1=Ax+A+Bx-B$$

$$1=(A+B)x+(A-B)$$

គេទាញបាន $\begin{cases}A+B=0\\A-B=1\end{cases}$ នាំឱ្យ $\begin{cases}A=\frac{1}{2}\\B=-\frac{1}{2}\end{cases}$

ដូចនេះ $\boxed{A=\frac{1}{2}\ ,B=-\frac{1}{2}}$ ។

ខ- គណនាអាំងតេក្រាល $I=\int_2^5 f(x).dx$

ចំពោះ $A=\frac{1}{2}\ ,B=-\frac{1}{2}$

គេបាន $f(x)=\frac{1}{2(x-1)}-\frac{1}{2(x+1)}$

គេបាន $I=\int_2^5 f(x).dx$

$$=\int_2^5\left[\frac{1}{2(x-1)}-\frac{1}{2(x+1)}\right].dx$$

$$=\frac{1}{2}\int_2^5\frac{1}{x-1}.dx-\frac{1}{2}.\int_2^5\frac{1}{x+1}.dx$$

$$=\frac{1}{2}.\int_2^5\frac{(x-1)'}{(x-1)}.dx-\frac{1}{2}.\int_2^5\frac{(x+1)'}{(x+1)}.dx$$

$$=\frac{1}{2}\left[\ln|x-1|\right]_2^5-\frac{1}{2}\left[\ln|x+1|\right]_2^5$$

$$=\frac{1}{2}[\ln 4-\ln 1]-\frac{1}{2}[\ln 6-\ln 3]$$

$$=\frac{1}{2}\ln 2^2-0-\frac{1}{2}\ln\left(\frac{6}{3}\right)=\ln 2-\frac{1}{2}\ln 2=\frac{1}{2}\ln 2=\ln\sqrt{2}$$

ដូចនេះ $I=\int_2^5 f(x).dx=\ln\sqrt{2}$ ។

## លំហាត់ទី៤៦

គេដឹងថា $\int_0^{x^2} f(2t-1).dt = 4x^6$ ។

ចូររកអនុគមន៍ $f(x)$ ។

## ដំណោះស្រាយ

រកអនុគមន៍ $f(x)$

គេមាន $\int_0^{x^2} f(2t-1).dt = 4x^6$

តាង $g(t) = f(2t-1)$ និង $G(t)$ ជាព្រីមីទីវនៃ $g(t)$ ។

គេបាន $\int_0^{x^2} g(t).dt = 4x^6$

$$\left[G(t)\right]_0^{x^2} = 4x^6$$

$$G(x^2) - G(0) = 4x^6$$

ធ្វើដេរីវេលើអង្គទាំងពីរនៃទំនាក់ទំនងនេះគេបាន :

$2x.G'(x^2) = 24x^5$ នាំឱ្យ $G'(x^2) = 12x^4$ ដោយ $G'(t) = g(t)$

គេទាញ $g(x^2) = 12x^4$ តែ $g(t) = f(2t-1)$

គេបាន $f(2x^2-1) = 12x^4$ តាង $2x^2 - 1 = y$ នាំឱ្យ $x^2 = \dfrac{y+1}{2}$

នាំឱ្យ $f(y)=12\left(\frac{y+1}{2}\right)^2=3(y+1)^2$ ។

ដូចនេះ $\boxed{f(x)=3(x+1)^2}$ ។

## លំហាត់ទី៤៧

១.ដោះស្រាយសមីការ $g''(x)-5g'(x)+6g(x)=0\ \ (E)$

២. កំនត់ចំលើយ $g(x)$ មួយនៃសមីការ $(E)$ ដែល $g(0)=0$ និង $g'(0)=1$

## ដំណោះស្រាយ

១. ដោះស្រាយសមីការ $g''(x)-5g'(x)+6g(x)=0\ \ (E)$

មានសមីការសំគាល់ $r^2-5r+6=0$

ដោយ $\Delta=25-24=1$ នាំឱ្យមានឫស $r_1=\frac{5-1}{2}=2\ \ ,r_2=\frac{5+1}{2}=3$

តាមរូបមន្ត $g(x)=A.e^{r_1x}+B.e^{r_2x}\ \ ,A,B\in IR$

ដូចនេះចំលើយសមីការជាអនុគមន៍ $g(x)=A.e^{2x}+B.e^{3x}\ \ ,A,B\in IR$ ។

២. កំនត់ចំលើយ $g(x)$ មួយនៃសមីការ $(E)$ ដែល $g(0)=0$ និង $g'(0)=1$

គេមាន $g(x) = A.e^{2x} + B.e^{3x}$ នាំឱ្យ $g'(x) = 2A.e^{2x} + 3B.e^{3x}$

តាមបំរាប់គេមាន $\begin{cases} g(0) = 0 \\ g'(0) = 1 \end{cases}$

សមមូល $\begin{cases} A + B = 0 \\ 2A + 3B = 1 \end{cases}$ នាំឱ្យ $\begin{cases} A = -1 \\ B = 1 \end{cases}$

ដូចនេះ $\boxed{g(x) = -e^{2x} + e^{3x}}$ ។

## លំហាត់ទី៤៨

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''-3y'+2y = 0$

ដោយដឹងថា $y(0) = 1$ , $y'(0) = 0$ ។

## ដំណោះស្រាយ

ដោះស្រាយសមីការឌីផេរ៉ង់ស្យែលៈ

$(E): y''-3y'+2y = 0$ មានសមីការសំគាល់ $r^2 - 3r + 2 = 0$

ដោយ $a + b + c = 0$ នាំឱ្យ $r_1 = 1$ , $r_2 = \frac{c}{a} = 2$

តាមរូបមន្ត $y = Ae^{r_1 x} + Be^{r_2 x}$

គេបាន $y = A.e^{x} + B.e^{2x}$ និង $y' = A.e^{x} + 2B.e^{2x}$ , $A, B \in IR$

ដោយតាមបំរាប់គេមាន $\begin{cases} y(0) = 1 \\ y'(0) = 0 \end{cases}$ ឬ $\begin{cases} A + B = 1 \\ A + 2B = 0 \end{cases}$ នាំឱ្យ $\begin{cases} A = 2 \\ B = -1 \end{cases}$

ដូចនេះ $y = 2e^{x} - e^{2x}$ ជាចំលើយសមីការ ។

## លំហាត់ទី៤៩

គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y''-4y'+4y = 4x^{2} - 24x + 34$

ក-កំនត់ចំនួនពិត $a, b$ និង $c$ ដើម្បីឱ្យអនុគមន៍ $y_{P}(x) = ax^{2} + bx + c$

ជាចំលើយដោយឡែកមួយរបស់សមីការ $(E)$ ។

ខ-បង្ហាញថាអនុគមន៍ $y = y_{P}(x) + y_{h}(x)$ ជាចំលើយទូទៅរបស់ $(E)$

លុះត្រាតែអនុគមន៍ $y_{h}(x)$ ជាចំលើយរបស់សមីការអូម៉ូសែន

$(E'): y''-4y'+4y = 0$ ។

គ-ដោះស្រាយសមីការ $(E')$ រួចទាញរកចំលើយទូទៅរបស់សមីការ $(E)$ ។

## ដំណោះស្រាយ

**ក. កំនត់ចំនួនពិត $a,b$ និង $c$**

$(E): y''-4y'+4y = 4x^2 - 24x + 34$

ដើម្បីឱ្យអនុគមន៍ $y_P(x) = ax^2 + bx + c$ ជាចំលើយដោយឡែកមួយ

របស់សមីការ $(E)$ លុះត្រាតែអនុគមន៍ $y_p(x), y'_p(x)$ និង $y''_p(x)$

ផ្ទៀងផ្ទាត់នឹងសមីការ $(E)$ ។

គេបាន$(E): y''_p(x) - 4y'_P(x) + 4y_p(x) = 4x^2 - 24x + 34$

ដោយ $\begin{cases} y_P(x) = ax^2 + bx + c \\ y'_p(x) = 2ax + b \\ y''_p(x) = 2a \end{cases}$

គេបាន $(2a) - 4(2ax + b) + 4(ax^2 + bx + c) = 4x^2 - 24x + 34$

នាំឱ្យ $4ax^2 + (4b - 8a)x + (2a - 4b + 4c) = 4x^2 - 24x + 34$

គេទាញបាន $\begin{cases} 4a = 4 \\ 4b - 8a = -24 \\ 2a - 4b + 4c = 34 \end{cases}$ នាំឱ្យ $\begin{cases} a = 1 \\ b = -4 \\ c = 4 \end{cases}$

ដូចនេះ $a = 1 \ \ ,b = -4 \ \ ,c = -4$ និង $y_P(x) = x^2 - 4x + 4 = (x-2)^2$ ។

ខ-ការបង្ហាញ

អនុគមន៍ $y = y_P(x) + y_h(x)$ ជាចំលើយរបស់ $(E)$ លុះត្រាអនុគមន៍

$y, y', y''$ ផ្ទៀងផ្ទាត់សមីការ ។

ដោយគេមាន $y' = y'_p(x) + y'_h(x)$ និង $y'' = y''_p(x) + y''_h(x)$

នោះគេបាន :

$$[y''_p(x) + y''_h(x)] - 4[y'_p(x) + y'_h(x)] + 4[y_p(x) + y_h(x)] = 4x^2 - 24x + 34$$

$$[y''_p(x) - 4y'_p(x) + 4y_p(x)] + [y''_h(x) - 4y'_h(x) + 4y_h(x)] = 4x^2 - 24x + 34 \quad (1)$$

តាមសម្រាយខាងលើគេមាន

$$y''_p(x) - 4y'_P(x) + 4y_p(x) = 4x^2 - 24x + 34 \quad (2)$$

( ព្រោះ $y_p(x)$ ជាចំលើយរបស់សមីការ $(E)$ ) ។

តាមទំនាក់ទំនង ( 1 ) និង ( 2) គេទាញបាន :

$$4x^2-24x+34+\left[y''_h(x)-4y'_h(x)+4y_h(x)\right]=4x^2-24x+34$$

$y''_h(x)-4y'_h(x)+4y_h(x)=0$ ទំនាក់ទំនងនេះបញ្ជាក់ថាអនុគមន៍ $y_h(x)$

ជាចំលើយរបស់សមីការ $(E'): y''-4y'+4y=0$ ។

គ-ដោះស្រាយសមីការ $(E'): y''-4y'+4y=0$

សមីការសំគាល់ $r^2-4r+4=0$ $,\Delta'=4-4=0$

នាំឱ្យសមីការមានឫសឌុប $r_1=r_2=r_0=2$ ។

ដូចនេះចំលើយសមីការ $(E')$ ជាអនុគមន៍

$$y_h(x)=(Ax+B).e^{2x} \quad ,A,B\in IR$$ ។

ទាញរកចំលើយទូទៅរបស់សមីការ $(E)$ ។

តាមសំរាយខាងលើចំលើយសមីការ $(E)$ គឺជាអនុគមន៍ទំរង់

$$y=y_p(x)+y_h(x)$$

ដោយគេមាន $y_p(x)=(x-2)^2$ និង $y_h(x)=(Ax+B).e^{2x}$

ដូចនេះ $y=(x-2)^2+(Ax+B).e^{2x}\quad ,A,B\in IR$

ជាចំលើយរបស់សមីការ ។

## លំហាត់ទី៥០

ក-ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E):f''(x)-f'(x)-6f(x)=0$

ខ-កំនត់អនុគមន៍ $y=f(x)$ ជាចំលើយមួយរបស់សមីការ $(E)$

បើគេដឹងថាខ្សែកោង $(C)$ តាង $f(x)$ ប៉ះទៅនឹងបន្ទាត់ $(T): y=-x+3$

ត្រង់ចំនុច $M(0,3)$ ។

## ដំណោះស្រាយ

ក-ដោះស្រាយសមីការឌីផេរ៉ង់ស្យែលៈ

$(E):f''(x)-f'(x)-6f(x)=0$

មានសមីការសំគាល់ $r^2-r-6=0$

$\Delta=1+24=25$ នាំឱ្យ $\left[\begin{array}{l} r_1=\dfrac{1-5}{2}=-2 \\ r_2=\dfrac{1+5}{2}=3 \end{array}\right.$

សមីការមានចំលើយជាអនុគមន៍ $f(x)=A.e^{-2x}+B.e^{3x}\quad ,A,B\in IR$ ។

ខ-កំនត់អនុគមន៍ $y = f(x)$

បើ $y = f(x)$ ជាចំលើយរបស់សមីការ $(E)$ នោះគេបាន :

$(C): y = f(x) = A.e^{-2x} + B.e^{3x}$

និង $y' = f'(x) = -2A.e^{-2x} + 3B.e^{3x}$ ។

ដើម្បីឱ្យខ្សែកោង $(C)$ តាង $f(x)$ ប៉ះទៅនឹងបន្ទាត់ $(T): y = -x + 3$

ត្រង់ចំនុច $M(0,3)$ លុះត្រាតែ $\begin{cases} f'(0) = -1 \\ f(0) = 3 \end{cases}$ ឬ $\begin{cases} -2A + 3B = -1 \\ A + B = 3 \end{cases}$

នាំឱ្យ $A = 2$ , $B = 1$ ។

ដូចនេះ $\boxed{y = f(x) = 2e^{-2x} + e^{3x}}$ ។

## លំហាត់ទី៥១

គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y'' + 9y = 0$

ក-ដោះស្រាយសមីការ $(E)$ ។

ខ-កំនត់អនុគមន៍ $f(x)$ ជាចំលើយមួយរបស់សមីការ $(E)$ បើគេដឹងថា :

$f(0) = \sqrt{3}$ , $f'(0) = 3$ ។

## ដំណោះស្រាយ

ក-ដោះស្រាយសមីការ $(E)$

$(E): y''+9y=0$ មានសមីការសំគាល់ $r^2+9=0$

$r^2=-9$ នាំឱ្យ $r_1=-3i$ ឬ $r_2=3i$

គេទាញបាន $\alpha=0$ និង $\beta=3$ ។

ចំលើយសមីការជាអនុគមន៍ទំរង់ $y=(A\cos\beta x+B\sin\beta x).e^{\alpha x}$

ដូចនេះ $\boxed{y = A\cos 3x + B\sin 3x}$ ។

ខ-កំនត់អនុគមន៍ $f(x)$

គេមាន $f(x)=A\cos 3x+B\sin 3x$

នាំឱ្យ $f'(x)=-3A\sin 3x+3B\cos 3x$

ដោយ $f(0)=A.\cos 0+B.\sin 0=\sqrt{3}$ នាំឱ្យ $A=\sqrt{3}$

និង $f'(0)=-3A\sin 0+3B\cos 0=3$ នាំឱ្យ $B=1$ ។

ដូចនេះ $\boxed{f(x)=\sqrt{3}\cos 3x+\sin 3x}$ ។

## លំហាត់ទី៥២

គេឱ្យសមីការឌីផេរ៉ង់ស្យែល : $y''-4y=8x-12 \quad (E)$

ក-កំនត់អនុគមន៍ $\varphi(x)=ax+b$ ជាចំលើយដោយឡែកមួយរបស់$(E)$ ។

ខ-រកចំលើយទូទៅរបស់សមីការ $(E)$ ។

## ដំណោះស្រាយ

ក-កំនត់អនុគមន៍ $\varphi(x)=ax+b$

គេមាន : $y''-4y=8x-12 \quad (E)$

បើ $\varphi(x)$ ជាចំលើយសមីការ $(E)$ នោះវាត្រូវផ្ទៀងផ្ទាត់នឹងសមីការ $(E)$ ។

គេបាន $\varphi''(x)-4\varphi(x)=8x-12 \quad (E_1)$

ដោយ $\varphi(x)=ax+b$ នាំឱ្យ $\varphi'(x)=a$ និង $\varphi''(x)=0$

សមីការ $(E_1)$ អាចសរសេរ: $0-4(ax+b)=8x-12$

$$-4ax-4b=8x-12$$

នាំឱ្យ $\begin{cases}-4a=8\\-4b=-12\end{cases}$ ឬ $\begin{cases}a=-2\\b=3\end{cases}$

ដូចនេះ $\boxed{\varphi(x)=-2x+3}$ ។

ខ-រកចំលើយទូទៅរបស់សមីការ $(E)$

ដកសមីការ $(E)$ និង $(E_1)$ គេបាន $(y''-\varphi''(x))-4(y-\varphi(x))=0$

តាង $z=y-\varphi(x)$ នាំឱ្យ $z'=y'-\varphi'(x)$ និង $z''=y''-\varphi''(x)$

គេបាន $z''-4z=0$ មានសមីការសំគាល់ $r^2-4=0$

មានឬស $r_1=-2, r_2=2$ ។

សមីការមានចំលើយ $z=A.e^{-2x}+B.e^{2x}$ ដែល $A,B\in IR$

ដោយ $z=y-\varphi(x)$ នាំឱ្យ $y=\varphi(x)+z$

ដូចនេះ $y=-2x+3+A.e^{-2x}+B.e^{2x}\ \ ,A,B\in IR$ ។

## <u>លំហាត់ទី៥៣</u>

គេឱ្យប្រវែងប្រែប្រួលមួយ $MN$ ដែល $MN=f(x)$ ។

អនុគមន៍ $f(x)$ ជាចំលើយសមីការឌីផេរ៉ង់ស្យែល :

$(E): f''(x)-2f'(x)+f(x)=0$ ។

ក-គណនាប្រវែង $MN$ បើគេដឹងថា $f(0)=2$ និង $f'(0)=1$ ។

ខ-កំនត់ប្រវែងអតិបរមានៃ $MN$ ។

## ដំណោះស្រាយ

ក-គណនាប្រវែង

$(E): f''(x) - 2f'(x) + f(x) = 0$ មានសមីការសំគាល់ $r^2 - 2r + 1 = 0$

$\Delta' = 1 - 1 = 0$ សមីកាសំគាល់មានឬសឌុប $r_1 = r_2 = r_0 = -\frac{b'}{a} = 1$

ចំលើយសមីការ $(E)$ ជាអនុគមន៍ $f(x) = (Ax + B).e^x$

ដោយ $f(0) = (A.0 + B).e^0 = 2$ នាំឱ្យ $B = 2$

ហើយ $f'(x) = (Ax + B)'.e^x + (e^x)'.(Ax + B)$

$$= A.e^x + e^x.(Ax + B)$$

ដោយ $f'(0) = A.e^0 + e^0(A.0 + B) = 1$ នាំឱ្យ $A = -1$

នាំអោយចំលើយដោយឡែកនៃសមីការ $(E)$ គឺជាអនុគមន៍

$f(x) = (-x + 2).e^x$

ដូចនេះប្រវែង $MN = f(x) = (-x + 2).e^x$ ដែល $x < 2$ ។

ខ-កំនត់ប្រវែងអតិបរមានៃ MN

គេមាន $MN = f(x) = (-x + 2).e^x$ ដែល $x < 2$

គេបាន $f'(x) = (-x + 2)'.e^x + (e^x)'.(-x + 2)$

$$= -e^x + e^x(-x + 2) = (-x + 1).e^x$$

បើ $f'(0)=(-x+1).e^{x}=0$ នាំឱ្យ $x=1$ ។

ចំពោះ $x=1$ នាំឱ្យ $f(1)=(-1+2).e^{1}=e=2,71828$ ។

គណនាដេរីវេទីពីរ $f''(x)=-e^{x}+(-x+1)e^{x}=-xe^{-x}$

ដោយ $f''(1)=-e^{-1}<0$ នាំឱ្យអនុគមន៍មានអតិបរមាត្រង់ $x=1$ ។

ដូចនេះប្រវែងអតិបរមានៃ MN គឺ $MN_{max}=e=2,71828$

(ឯកតាប្រវែង) ។

## លំហាត់ទី៥៤

គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y''+4y=0$ ។

ក-ដោះស្រាយសមីការ $(E)$ ។

ខ-កំនត់អនុគមន៍ $f(x)$ ជាចំលើយមួយនៃសមីការ $(E)$ បើគេដឹងថា

$f(0)=1$ និង $f'(0)=2\sqrt{3}$ ។

គ-ចូរសរសេរអនុគមន៍ $f(x)$ ជារាង $f(x)=k.\cos(\omega x+\varphi)$

ដែល $k$ ,$\omega$ និង $\varphi$ ជាបីចំនួនពិត ។

ឃ-គណនាអាំងតេក្រាល $I=\int_{0}^{\frac{\pi}{3}}\frac{dx}{f^{2}(x)}$ ។

## ដំណោះស្រាយ

ក-ដោះស្រាយសមីការ $(E)$

$(E): y''+4y=0$ មានសមីការសំគាល់ $r^2+4=0$

នាំឱ្យ $r_1=-2i\ \ ,r_2=2i$ គេទាញបាន $\alpha=0\ \ ,\beta=2$ ។

ចំលើយសមីការ $(E)$ ជាអនុគមន៍ទំរង់ $y=(A\cos\beta x+B\sin\beta x).e^{\alpha x}$

ដូចនេះ $y=A\cos 2x+B\sin 2x$ ដែល $A,B\in IR$ ។

ខ-កំនត់អនុគមន៍ $f(x)$

គេមាន $f(x)=A\cos 2x+B\sin 2x$

នាំឱ្យ $f'(x)=-2A\sin 2x+2B\cos 2x$

ដោយ $f(0)=A.\cos 0+B.\sin 0=1$ នាំឱ្យ $A=1$

និង $f'(0)=-2A\sin 0+2B\cos 0=2\sqrt{3}$ នាំឱ្យ $B=\sqrt{3}$

ដូចនេះ $f(x)=\cos 2x+\sqrt{3}.\sin 2x$ ។

គ-សរសេរអនុគមន៍ $f(x)$ ជារាង $f(x)=k.\cos(\omega x+\varphi)$

គេមាន $f(x)=\cos 2x+\sqrt{3}.\sin 2x$ ដោយ $\tan\frac{\pi}{3}=\sqrt{3}$

គេបាន $f(x)=\cos 2x+\tan\frac{\pi}{3}.\sin 2x$

$$= \cos 2x + \frac{\sin\frac{\pi}{3}}{\cos\frac{\pi}{3}}.\sin 2x = \frac{1}{\cos\frac{\pi}{3}}\left(\cos 2x \cos\frac{\pi}{3} + \sin 2x \sin\frac{\pi}{3}\right)$$

$$= 2.\cos\left(2x - \frac{\pi}{3}\right)$$

ដូចនេះ $f(x) = 2\cos\left(2x - \frac{\pi}{3}\right) = k.\cos(\omega x + \varphi)$

ឃ-គណនាអាំងតេក្រាល $I = \int_0^{\frac{\pi}{3}} \frac{dx}{f^2(x)}$

ដោយគេមាន $f(x) = 2\cos\left(2x - \frac{\pi}{3}\right)$

គេបាន $I = \int_0^{\frac{\pi}{3}} \frac{dx}{4\cos^2\left(2x - \frac{\pi}{3}\right)} = \frac{1}{4}.\int_0^{\frac{\pi}{3}} \frac{dx}{\cos^2\left(2x - \frac{\pi}{3}\right)}$

តាង $u = 2x - \frac{\pi}{3}$ នាំឱ្យ $du = 2.dx$ ឬ $\frac{1}{2}.du = dx$

ចំពោះ $x \in \left[0, \frac{\pi}{3}\right]$ នាំឱ្យ $u \in \left[-\frac{\pi}{3}, \frac{\pi}{3}\right]$

គេបាន $I = \frac{1}{4}.\int_{-\frac{\pi}{3}}^{\frac{\pi}{3}} \frac{\frac{1}{2}.du}{\cos^2 u} = \frac{1}{8}.\int_{-\frac{\pi}{3}}^{\frac{\pi}{3}} \frac{du}{\cos^2 u} = \frac{1}{8}.[\tan u]_{-\frac{\pi}{3}}^{\frac{\pi}{3}} = \frac{1}{8}\left(\sqrt{3} + \sqrt{3}\right) = \frac{\sqrt{3}}{4}$

ដូចនេះ $\boxed{I = \int_0^{\frac{\pi}{3}} \frac{dx}{f^2(x)} = \frac{\sqrt{3}}{4}}$ ។

## លំហាត់ទី៥៥

គេឱ្យអាំងតេក្រាល $I_n = \int_0^1 \frac{e^{nx}}{e^x+1}.dx \, , n \in IN$ ។

ក-គណនា $I_0 + I_1$ , $I_1$ រួចទាញរក $I_0$ ។

ខ-គណនា $I_n + I_{n+1}$ ជាអនុគមន៍នៃ n ។

## ដំណោះស្រាយ

ក-គណនា $I_0 + I_1$ , $I_1$ រួចទាញរក $I_0$

យើងមាន $I_0 = \int_0^1 \frac{1}{e^x+1}.dx$ , $I_1 = \int_0^1 \frac{e^x}{e^x+1}$

យើងបាន

$$I_0 + I_1 = \int_0^1 \frac{1}{e^x+1}.dx + \int_0^1 \frac{e^x}{e^x+1}.dx = \int_0^1 \frac{1+e^x}{e^x+1}.dx = \int_0^1 dx = 1$$

$$I_1 = \int_0^1 \frac{e^x}{e^x+1}.dx = \int_0^1 \frac{(e^x+1)'}{(e^x+1)}.dx = \left[\ln(e^x+1)\right]_0^1 = \ln(e+1) - \ln 2 = \ln\frac{e+1}{2}$$

ដោយ $I_0 + I_1 = 1$ នាំឱ្យ $I_0 = 1 - I_1 = 1 - \ln(\frac{e+1}{2})$ ។

ដូចនេះ $\boxed{I_0 + I_1 = 1 \, , \; I_1 = \ln\left(\frac{e+1}{2}\right) \, , I_0 = 1 - \ln\left(\frac{e+1}{2}\right)}$ ។

ខ-គណនា $I_n + I_{n+1}$ ជាអនុគមន៍នៃ n

យើងបាន $I_n + I_{n+1} = \int_0^1 \frac{e^{nx}}{e^x+1}.dx + \int_0^1 \frac{e^{(n+1)x}}{e^x+1}.dx$

$$= \int_0^1 \frac{e^{nx} + e^{(n+1)x}}{e^x + 1}.dx = \int_0^1 \frac{e^{nx}(1+e^x)}{e^x+1}.dx$$

$$= \int_0^1 e^{nx}.dx = \left[\frac{1}{n}e^{nx}\right]_0^1 = \frac{e^n - 1}{n}$$

ដូចនេះ $\boxed{I_n + I_{n+1} = \frac{e^n - 1}{n}}$ ។

## លំហាត់ទី៥៦

គេឱ្យអនុគមន៍ $f$ កំនត់លើ $IR - \{-1\}$ ហើយផ្ទៀងផ្ទាត់ទំនាក់ទំនង:

$$x^2 f\left(x^3\right) + \frac{1}{(1+x)^2} f\left(\frac{1-x}{1+x}\right) = 4x^3\left(1+x^4\right)^5$$

ចូរគណនាអាំងតេក្រាល: $I = \int_0^1 f(x).dx$ ។

## ដំណោះស្រាយ

គណនាអាំងតេក្រាល: $I = \int_0^1 f(x).dx$

តាង $x = t^3$ នាំឱ្យ $dx = 3t^2.dt$

ចំពោះ $x \in [\ 0,1\ ]$ នាំឱ្យ $t \in [\ 0,1\ ]$

គេបាន $I = \int_0^1 f(x).dx = \int_0^1 f(t^3).3t^2 dt$

នាំឱ្យ $\frac{1}{3} I = \int_0^1 t^2 f(t^3).dt \quad (1)$

ម្យ៉ាងទៀតបើគេតាង $x = \frac{1-t}{1+t}$ នាំឱ្យ $dx = -\frac{2dt}{(1+t)^2}$

ចំពោះ $x \in [\,0,1\,]$ នាំឱ្យ $t \in [1,0]$

គេបាន $I = \int_0^1 f(x).dx = \int_1^0 f\left(\frac{1-t}{1+t}\right).(-\frac{2dt}{(1+t)^2}) = 2\int_0^1 \frac{1}{(1+t)^2} f(\frac{1-t}{1+t}).dt$

គេទាញបាន $\frac{1}{2}I = \int_0^1 \frac{1}{(1+t)^2} f(\frac{1-t}{1+t}).dt \quad (2)$

បូកទំនាក់ទំនង (1) និង (2) គេបាន :

$$\frac{1}{3}I + \frac{1}{2}I = \int_0^1 \left[ t^2 f(t^3) + \frac{1}{(1+t)^2} f(\frac{1-t}{1+t}) \right].dt$$

តាមសម្មតិកម្មគេមាន $x^2 f(x^3) + \frac{1}{(1+x)^2} f\left(\frac{1-x}{1+x}\right) = 4x^3(1+x^4)^5$

គេបាន $\frac{5}{6}I = \int_0^1 4t^3(1+t^4)^5.dt = \left[\frac{1}{6}(1+t^4)^6\right]_0^1 = \frac{64}{6} - \frac{1}{6} = \frac{63}{6}$

ដូចនេះ $\boxed{I = \int_0^1 f(x).dx = \frac{63}{5}}$ ។

## លំហាត់ទី៥៧

គេសន្មត់ថា f ជាអនុគមន៍មួយកំនត់លើ IR ហើយផ្ទៀងផ្ទាត់ទំនាក់ទំនង៖

$f(x)+f(-x)=\sqrt{2-2\cos 2x}$ ។

ចូរគណនា $I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}} f(x).dx$ ។

## ដំណោះស្រាយ

គណនា $I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}} f(x).dx$

យើងមាន $I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}} f(x).dx=\int_{-\frac{\pi}{3}}^{0} f(x).dx+\int_{0}^{\frac{\pi}{3}} f(x).dx$

តាង $x=-t$ នាំឱ្យ $dx=-dt$ និង ចំពោះ $x\in\left[-\frac{\pi}{3}\ ,\ 0\right]$

នាំឱ្យ $t\in\left[\frac{\pi}{3},0\right]$ ។

គេបាន $\int_{-\frac{\pi}{3}}^{0} f(x).dx=\int_{\frac{\pi}{3}}^{0} f(-t).(-dt)=\int_{0}^{\frac{\pi}{3}} f(-t).dt=\int_{0}^{\frac{\pi}{3}} f(-x).dx$

គេទាញ $I=\int_0^{\frac{\pi}{3}} f(-x).dx+\int_0^{\frac{\pi}{3}} f(x).dx=\int_0^{\frac{\pi}{3}}[f(-x)+f(x)].dx$

ដោយ $f(x)+f(-x)=\sqrt{2-2\cos 2x}=\sqrt{4\sin^2 x}=2|\sin x|$

គេបាន $I=\int_0^{\frac{\pi}{3}} 2|\sin x|.dx=2\int_0^{\frac{\pi}{3}}\sin x.dx=2[-\cos x]_0^{\frac{\pi}{3}}=2\left(-\frac{1}{2}+1\right)=1$

ដូចនេះ $\boxed{I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}} f(x).dx=1}$ ។

## លំហាត់ទី៥៨

ចូរបង្ហាញថា $\int_a^b f(x).dx=\int_a^b f(a+b-x).dx$

អនុវត្តន៍ ៖ ចូរគណនា $I=\int_0^{\frac{\pi}{3}}\log_2(1+\sqrt{3}\tan x).dx$

## ដំណោះស្រាយ

បង្ហាញថា $\int_a^b f(x).dx=\int_a^b f(a+b-x).dx$

តាង $x=a+b-t$ នាំឱ្យ $dx=-dt$ ចំពោះ $x\in[a,b]$ នាំឱ្យ $t\in[b,a]$

គេបាន $\int_a^b f(x).dx=\int_b^a f(a+b-t)(-dt)=\int_a^b f(a+b-t).dt$

ដូចនេះ $\boxed{\int_a^b f(x).dx=\int_a^b f(a+b-x).dx}$ ។

អនុវត្តន៍ ៖ គណនា $I = \int_0^{\frac{\pi}{3}} \log_2(1+\sqrt{3}\tan x).dx$

យើងបាន $I = \int_0^{\frac{\pi}{3}} \log_2\left[1+\sqrt{3}\tan(\frac{\pi}{3}-x)\right].dx$

$$I = \int_0^{\frac{\pi}{3}} \log_2\left[1+\sqrt{3}.\frac{\sqrt{3}-\tan x}{1+\sqrt{3}\tan x}\right].dx$$

$$I = \int_0^{\frac{\pi}{3}} \log_2\left(\frac{1+\sqrt{3}\tan x+3-\sqrt{3}\tan x}{1+\sqrt{3}\tan x}\right).dx$$

$$I = \int_0^{\frac{\pi}{3}} \log_2\left(\frac{4}{1+\sqrt{3}\tan x}\right).dx = \int_0^{\frac{\pi}{3}} \left[\log_2 4 - \log_2(1+\sqrt{3}\tan x)\right].dx$$

$$I = \int_0^{\frac{\pi}{3}} \log_2 4.dx - \int_0^{\frac{\pi}{3}} \log_2(1+\sqrt{3}\tan x).dx = \frac{\pi}{3}\log_2 2^2 - I = \frac{2\pi}{3} - I$$

នាំឱ្យគេទាញបាន $\boxed{I = \frac{\pi}{3}}$ ។

## លំហាត់ទី៥៩

គេឱ្យ f ជាអនុគមន៍ជាប់លើ $[0,1]$ ។

ចូរបង្ហាញថា $\int_0^{\pi} x.f(\sin x).dx = \frac{\pi}{2}\int_0^{\pi} f(\sin x).dx$ ?

អនុវត្តន៍: ចូរគណនា $I = \int_0^{\pi} \frac{x\sin x.dx}{1+\cos^2 x}$ ។

## ដំណោះស្រាយ

បង្ហាញថា $\int_0^{\pi} x.f(\sin x).dx = \frac{\pi}{2}\int_0^{\pi} f(\sin x).dx$

តាង $x = \pi - t$ នាំឱ្យ $dx = -dt$

ចំពោះ $x \in [0,\pi]$ នាំឱ្យ $t \in [\pi, 0]$

គេបាន $\int_0^{\pi} x.f(\sin x).dx = -\int_{\pi}^{0} (\pi - t).f[\sin(\pi - t)].dt$

$$\int_0^{\pi} x.f(\sin x).dx = \int_0^{\pi} (\pi - t).f(\sin t).dt = \pi\int_0^{\pi} f(\sin t).dt - \int_0^{\pi} t.f(\sin t).dt$$

$$\int_0^{\pi} x.f(\sin x).dx = \pi\int_0^{\pi} f(\sin x).dx - \int_0^{\pi} x.f(\sin x).dx$$

នាំឱ្យគេទាញបាន $\int_0^{\pi} x.f(\sin x).dx = \frac{\pi}{2}\int_0^{\pi} f(\sin x).dx$ ។

អនុវត្តន៍: គណនា $I = \int_0^{\pi} \frac{x\sin x.dx}{1+\cos^2 x}$

គេមាន $I=\int_0^\pi \frac{x.\sin x.dx}{1+\cos^2 x}=\int_0^\pi x.\frac{\sin x.dx}{2-\sin^2 x}=\frac{\pi}{2}\int_0^\pi \frac{\sin x.dx}{2-\sin^2 x}$

តាង $z=\cos x$ នាំឱ្យ $dz=-\sin x.dx$

ហើយចំពោះ $x\in[0,\pi]$ នោះ $z\in[1,-1]$

គេបាន $I=\frac{\pi}{2}\int_1^{-1}\frac{-dz}{1+z^2}=\frac{\pi}{2}[\arctan z]_{-1}^{1}=\frac{\pi}{2}\left(\frac{\pi}{4}+\frac{\pi}{4}\right)=\frac{\pi^2}{4}$ ។

ដូចនេះ $\boxed{I=\int_0^\pi \frac{x\sin x.dx}{1+\cos^2 x}=\frac{\pi^2}{4}}$ ។

## លំហាត់ទី៦០

គេឱ្យ $f$ ជាអនុគមន៍គូលើ $[-a,a]$ ។

ក. ចូរបង្ហាញថា $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_0^a f(x).dx$ , $q>0$ , $q\neq 1$ ។

ខ. អនុវត្តន៍ ៖ គណនា $I=\int_{-\frac{\pi}{2}}^{\frac{\pi}{2}}\frac{\cos x}{1+3^x}.dx$

## ដំណោះស្រាយ

ក.បង្ហាញថា $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_0^a f(x).dx$ , $q>0$ , $q\neq 1$ ។

គេមាន $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_{-a}^{0}\frac{f(x).dx}{1+q^x}+\int_0^a\frac{f(x).dx}{1+q^x}$ $(1)$

តាង $x=-t$ នាំឱ្យ $dx=-dt$ និងចំពោះ $x\in[-a,0]$ នាំឱ្យ $t\in[a,0]$

គេបាន $\int_{-a}^{0}\frac{f(x).dx}{1+q^x}=-\int_{a}^{0}\frac{f(-t).dt}{1+q^{-t}}=\int_{0}^{a}\frac{q^t.f(-t)dt}{1+q^t}=\int_{0}^{a}\frac{q^x f(-x).dx}{1+q^x}$

ដោយ $f(x)$ ជាអនុគមន៍គូនោះ $f(-x)=f(x)\ ,\ \forall x\in[-a,a]$

គេទាញបាន $\int_{-a}^{0}\frac{f(x).dx}{1+q^x}=\int_{0}^{a}\frac{q^x.f(x)}{1+q^x}.dx\ (2)$

យក (2) ទៅជំនួសក្នុង (1) គេបាន ៖

$$\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_{0}^{a}\frac{q^x.f(x).dx}{1+q^x}+\int_{0}^{a}\frac{f(x).dx}{1+q^x}=\int_{0}^{a}\frac{(q^x+1)f(x).dx}{1+q^x}=\int_{0}^{a}f(x).dx$$

ដូចនេះ $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_{0}^{a}f(x).dx\ ,\ q>0\ ,q\neq 1$ ។

ខ. អនុវត្តន៍ ៖ គណនា $I=\int_{-\frac{\pi}{2}}^{\frac{\pi}{2}}\frac{\cos x}{1+3^x}.dx$

ដោយ $\cos x$ ជាអនុគមន៍គូនោះគេបាន ៖

$$I=\int_{0}^{\frac{\pi}{2}}\cos x.dx=[\sin x]_{0}^{\frac{\pi}{2}}=1-0=1$$ ។

ដូចនេះ $\boxed{I=1}$ ។

## លំហាត់ទី៦១

ក-គណនាអាំងតេក្រាលកំនត់ $I_n = \int_0^1 (1+x)^n .dx \quad ,n \in IN$ ។

ខ-ទាញបង្ហាញថា $C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + ..... + \frac{1}{n+1}C_n^n = \frac{2^{n+1}-1}{n+1}$

## ដំណោះស្រាយ

ក-គណនាអាំងតេក្រាលកំនត់

$$I_n = \int_0^1 (1+x)^n .dx \quad ,n \in IN$$

$$= \left[\frac{1}{n+1}(1+x)^{n+1}\right]_0^1 = \frac{1}{n+1}.2^{n+1} - \frac{1}{n+1}$$

$$= \frac{2^{n+1}-1}{n+1}$$

ខ-ទាញបង្ហាញថា $C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + ..... + \frac{1}{n+1}C_n^n = \frac{2^{n+1}-1}{n+1}$

តាមរូបមន្តទ្វេធាញូតុនគេមាន :

$$(1+x)^n = C_n^0 + C_n^1 x + C_n^2 x^2 + .......... + C_n^n x^n$$

ធ្វើអាំងតេក្រាលកំនត់ក្នុងចន្លោះ [0,1] នៃសមភាពនេះគេបាន :

$$\int_0^1 (1+x)^n.dx = \int_0^1 \left(C_n^0 + C_n^1 x + C_n^2 x^2 + ..... + C_n^n x^n\right).dx$$

$$\frac{2^{n+1}-1}{n+1} = \left[C_n^0 x + \frac{1}{2}C_n^1 x^2 + \frac{1}{3}C_n^2 x^3 + ...... + \frac{1}{n+1}C_n^n x^{n+1}\right]_0^1$$

$$\frac{2^{n+1}-1}{n+1} = C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + ........... + \frac{1}{n+1}C_n^n$$

ដូចនេះ $\boxed{C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + ..... + \frac{1}{n+1}C_n^n = \frac{2^{n+1}-1}{n+1}}$ ។

## លំហាត់ទី៦២

គេមានស៊ីត $(I_n)$ កំនត់ចំពោះគ្រប់ $n \geq 1$ ដោយ

$$I_n = \frac{1}{n!}.\int_0^1 (1-x)^n.e^x.dx$$

ក-ចូរគណនាតួ $I_1$ ។

ខ-ចូរបញ្ជាក់ $I_{n+1}$ ជាអនុគមន៍នៃ $I_n$ រួចទាញឱ្យបានថា $I_n = e - \sum_{p=0}^{n}\left(\frac{1}{P!}\right)$

គ-ចូររកលីមីត $\lim_{n\to+\infty} I_n$ ។

ទាញថា $\lim_{n\to+\infty}\left(1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+....+\frac{1}{n!}\right) = e = 2.71828$

## ដំណោះស្រាយ

ក-ចូរគណនាតួ $I_1$

គេមាន $I_1 = \frac{1}{1!}\int_0^1 (1-x)e^x.dx = \int_0^1 (1-x).e^x.dx$

តាង $\begin{cases} u = 1-x \\ dv = e^x dx \end{cases}$ នាំឱ្យ $\begin{cases} du = -dx \\ v = e^x \end{cases}$

គេបាន $I = \left[(1-x)e^x\right]_0^1 - \int_0^1 e^x(-dx) = -1 + \left[e^x\right]_0^1 = e-2$

ដូចនេះ $\boxed{I = e-2}$ ។

ខ-បញ្ជាក់ $I_{n+1}$ ជាអនុគមន៍នៃ $I_n$

គេមាន $I_n = \frac{1}{n!}.\int_0^1 (1-x)^n.e^x.dx$

នាំឱ្យ $I_{n+1} = \frac{1}{(n+1)!}.\int_0^1 (1-x)^{n+1}.e^x dx$

តាង $\begin{cases} u = (1-x)^{n+1} \\ dv = e^x dx \end{cases}$ នាំឱ្យ $\begin{cases} du = -(n+1)(1-x)^n \\ v = e^x \end{cases}$

គេបាន $I_{n+1} = \frac{1}{(n+1)!}\left[(1-x)^{n+1}e^x\right]_0^1 + \frac{n+1}{(n+1)!}\int_0^1 (1-x)^n e^x.dx$

$$I_{n+1} = -\frac{1}{(n+1)!} + \frac{1}{n!}\int_0^1 (1-x)^n e^x.dx = \frac{1}{(n+1)!} + I_n$$

ដូចនេះ $\boxed{I_{n+1} = I_n - \frac{1}{(n+1)!}}$ ។

ទាញឱ្យបានថា $I_n = e - \sum_{p=0}^{n}\left(\frac{1}{P!}\right)$

គេមាន $I_{n+1} = I_n - \frac{1}{(n+1)!}$

ចំពោះ $n = 1 \ : I_2 = I_1 - \frac{1}{2!}$

ចំពោះ $n = 2 : I_3 = I_2 - \frac{1}{3!}$

....................................................

ចំពោះ $n = n-1 : I_n = I_{n-1} - \frac{1}{n!}$

ដោយធ្វើផលបូកទំនាក់ទំនងនេះអង្គ និង អង្គ គេបាន :

$I_n = I_1 - \frac{1}{2!} - \frac{1}{3!} - .... - \frac{1}{n!}$ ដោយ $I_1 = e - 2 = e - \frac{1}{0!} - \frac{1}{1!}$

ដូចនេះ $\boxed{I_n = e - \frac{1}{0!} - \frac{1}{1!} - \frac{1}{2!} - .... - \frac{1}{n!} = e - \sum_{p=0}^{n}\left(\frac{1}{p!}\right)}$ ។

គ-ចូររកលីមីត $\lim_{n\to+\infty} I_n$

ចំពោះ $x \in [0, 1]$ គេមាន $1 \le e^x \le e$ និង $(1-x)^n \ge 0$

គេបាន $(1-x)^n \le e^x(1-x)^n \le e(1-x)^n$

នាំឱ្យ $\frac{1}{n!}\int_0^1 (1-x)^n .dx \le \frac{1}{n!}\int_0^1 (1-x)^n e^x .dx \le \frac{e}{n!}\int_0^1 (1-x)^n .dx$

ដោយ $\int_0^1 (1-x)^n .dx = \left[-\frac{1}{n+1}(1-x)^{n+1}\right]_0^1 = \frac{1}{n+1}$

គេទាញបាន $\frac{1}{n!(n+1)} \le I_n \le \frac{e}{n!(n+1)}$ ។

កាលណា $n \to +\infty$ នាំឱ្យ $\frac{1}{n!(n+1)} \to 0$

ដូចនេះ $\boxed{\lim_{n\to+\infty} I_n = 0}$ ។

ទាញថា $\lim_{n\to+\infty}\left(1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+....+\frac{1}{n!}\right) = e = 2.71828$

គេមាន $I_n = e - \sum_{p=0}^{n}\left(\frac{1}{p!}\right)$ នាំឱ្យ $\sum_{p=0}^{n}\left(\frac{1}{p!}\right) = e - I_n$

គេបាន $\lim_{n\to+\infty}\sum_{p=0}^{n}\left(\frac{1}{p!}\right) = \lim_{n\to+\infty}(e - I_n) = e$ ព្រោះ $\lim_{n\to+\infty} I_n = 0$

ដូចនេះ $\boxed{\lim_{n\to+\infty}\left(1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+....+\frac{1}{n!}\right) = e = 2.71828}$ ។

# លំហាត់អនុវត្តន៍

**1**.គេឲ្យចំនួនកុំផ្លិច $z = x + iy$ ដែល $x$ និង $y$ ជាចំនួនពិត ។

ចូរកំនត់តម្លៃ $x$ និង $y$ បើគេដឹងថា ៖

$$\frac{5(1+i)}{2-i}.z + \frac{1+12i}{1+2i}.\overline{z} = \frac{7-11i}{1-i}$$

**2**.ក_គេឲ្យ $z = \frac{1+i\sqrt{3}}{2}$ ។

ចូរសរសេរ $z^9$ និង $z^{2009}$ ជាទម្រង់ពីជគណិត ។

ខ.កំនត់ពីរចំនួនពិត $p$ និង $q$ ដើម្បីឲ្យ $z = \frac{1+i\sqrt{3}}{2}$ ជាឫស

របស់សមីការ $z^{2009} + pz^9 + q = 0$ ។

**3**.គេឲ្យចំនួនកុំផ្លិច $z = \sqrt{2-\sqrt{2}} + i.\sqrt{2+\sqrt{2}}$

ចូរសរសេរ $z^2$ និង $z$ ជាទម្រង់ត្រីកោណមាត្ររួចទាញរកតម្លៃ

ប្រាកដនៃ $\cos\frac{\pi}{8}$ និង $\sin\frac{\pi}{8}$ ។

**4**.គេឲ្យចំនួនកុំផ្លិច $z = -\frac{1}{2} + i.\frac{\sqrt{3}}{2}$ និង $W = \frac{1+z^{2009}}{1-z}$

ចូរសរសេរ $z$ និង $W$ ជាទម្រង់ត្រីកោណមាត្រ ។

5 .ដោះស្រាយសមីការ $z^2 - 2(1+i\sqrt{3})z - 1 + 2i\sqrt{3} = 0$

6 .គេតាង $z_1$ និង $z_2$ ជាឬសរបស់សមីការ $z^2 - \sqrt{3}z + 1 = 0$

ចូរគណនា $S = z_1^{2009} + z_2^{2009}$ ។

7 .ដោះស្រាយសមីការ $|1+z| + 2z = 9 + 8i$

8 .គេឲ្យចំនួនកុំផ្លិច $\alpha = 3 + i\sqrt{3}$ និង $\beta = 1 + i\sqrt{3}$

គេតាង $Z_n = (\alpha+\beta)(\alpha^2+\beta^2)....(\alpha^{2^n}+\beta^{2^n})$ ។

ចូរកំនត់រកផ្នែកពិត និង ផ្នែកនិម្មិតនៃ $Z_n$ ។

9 .គេឲ្យចំនួនកុំផ្លិច $z_n = \dfrac{1}{n^2 + n - 1 + i.(2n+1)}$

ដែល $n \in IN$ ។

ក.កំនត់ពីរចំនួនពិត A និង B បើគេដឹងថា ៖

$$Z_n = \frac{A}{n+i} + \frac{B}{n+1+i}$$

ខ.គណនាផលបូក $S_n = \sum_{k=0}^{n} (Z_k) = Z_0 + Z_1 + .... + Z_n$

ដោយសរសេរលទ្ធផលជារាងពីជគណិត ។

10 .គេឲ្យចំនួនកុំផ្លិច $z = -1 + i\sqrt{2}$ ។

គេតាង $S_n = z^2 + \overline{z}^n$ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីហ្វ n ។

ចូរបង្ហាញថា $S_{n+2} + 2S_{n+1} + 3S_n = 0$ ។

**11**.គេឲ្យចំនួនកុំផ្លិច $w = \dfrac{\sqrt{6} - i\sqrt{2}}{1 - i}$

ចូរសរសេរ $w$ ជាទម្រង់ពីជគណិត និង ជាទម្រង់ត្រីកោណមាត្រ

រួចទាញរកតម្លៃប្រាកដនៃ $\cos\dfrac{\pi}{12}$ និង $\sin\dfrac{\pi}{12}$ ។

**12**.គេឲ្យចំនួនកុំផ្លិច ៖

$$z = (\cos^2 x + \frac{1}{\cos^2 x}) + i.(\sin^2 x + \frac{1}{\sin^2 x})$$

ដែល $0 < x < \dfrac{\pi}{2}$ ។

ចូរគណនាតម្លៃតូចបំផុតនៃម៉ូឌុលរបស់ $z$ ។

**13**.គេឲ្យចំនួនកុំផ្លិច ៖

$$z = 2(a+1)(2a-3) + i(a-4)(3a-2)$$

ដែល $a$ ជាចំនួនពិត ។

ក.ចូរស្រាយថា $|z| = 5(a^2 - 2a + 2)$

ខ.ក្នុងប្លង់កុំផ្លិច $(o, \vec{i}, \vec{j})$ គេសន្មតថា $M$ ជារូបភាពនៃ $z$ ។

កំនត់ទីតាំង $M$ ដើម្បីឲ្យចម្ងាយ $OM$ ខ្លីបំផុត ។

**14**.ក្នុងប្លង់កុំផ្លិច $(o,\vec{i},\vec{j})$ គេឲ្យបួនចំនុច $A , B , C$ និង $D$ មានអាហ្វិករៀងគ្នា $-2+4i , 4-2i , 5-i$ និង $6+2i$ ។

ក.ចូរដៅចំនុច $A , B , C$ និង $D$ ។

ខ.ចូរស្រាយថាចតុកោណ $ABCD$ ចារិកក្នុងរង្វង់មួយ ។

**15**.គេមានសមីការ $(E): 2z^4+3z^2+3\sqrt{3}z+9=0$

ក.បង្ហាញថាបើ $z_0$ ជាឬសរបស់សមីការ $(E)$ នោះ $\bar{z}_0$ ក៏ជាឬសរបស់សមីការ $(E)$ ដែរ ។

ខ.ដោះស្រាយក្នុងសំណុំចំនួនកុំផ្លិចនូវសមីការ $(E)$ ដោយដឹងថាឬសមួយរបស់វាមានទម្រង់ $a(1+i)$ ដែល $a\in IR$ ។

**16**.គេឲ្យចំនួនកុំផ្លិច $z=\frac{1}{2}+\cos\frac{\pi}{5}+i\sin\frac{2\pi}{5}$

ក.បង្ហាញថា $\cos\frac{\pi}{5}-\cos\frac{2\pi}{5}=\frac{1}{2}$

ខ.ចូរសរសេរ $z$ ជាទម្រង់ត្រីកោណមាត្រ ។

**17**.គេឲ្យសមីការ ៖

$$(E): z^3-(1+3i)z^2+(1+2i)z-3-3i=0$$

ក.កំនត់ចំនួនពិត $b$ ដើម្បីឲ្យ $z=i.b$ ជាឬសរបស់ $(E)$

ខ.ដោះស្រាយក្នុងសំណុំចំនួនកុំផ្លិចនូវសមីការ (E) ។

**18**.ក្នុងប្លង់កុំផ្លិច $(o,\vec{i},\vec{j})$ គេឲ្យចំនុច M មានអាហ្វិក z ផ្ទៀងផ្ទាត់ទំនាក់ទំនង $\left|\frac{z-2+2i}{z+1+i}\right|=\frac{\sqrt{2}}{2}$ ។

ចូររក និងសង់សំណុំចំនុច M ។

**19**.គេឲ្យសមីការដឺក្រេទីពីរ ៖

$$(E): z^2-(\sqrt{3}-1+2i)z-\sqrt{3}-1+i\sqrt{3}-i=0$$

ក.ដោះស្រាយក្នុងសំណុំចំនួនកុំផ្លិចនូវសមីការ (E) ។

ខ.សរសេរឬសទាំងពីរនៃសមីការ (E)ជារាងត្រីកោណមាត្រ ។

**20**.គេឲ្យពហុធា $P(z)=\left(\frac{z^2+z-1}{2}\right)^{2009}$ ដែល z ជាចំនួនកុំផ្លិច។

ចូររកអនុគមន៍សំណល់នៃវិធីចែករវាង P(z) នឹង $z^2-z+1$

**21**.គេឲ្យសមីការ $(E): z^2+(4+4i)z+(7+32i)=0$

ក.កំនត់ឬស $z_1$ និង $z_2$ នៃសមីការ (E)ដែល $|z_1|<|z_2|$។

ខ.ក្នុងប្លង់កុំផ្លិច $(o,\vec{i},\vec{j})$ គេតាង A,B,C ជារូបភាពរៀងគ្នានៃចំនួនកុំផ្លិច $i, z_1, z_2$ ។ ចូរដៅចំនុចទាំងនេះ ។

គ. $G$ ជាបារីសង់នៃប្រព័ន្ធ $(A;2),(B;-2)$ និង $(C;-1)$ ។

ចូររកអាហ្វិកនៃចំនុច $G$ ។

$22$ .គេឲ្យស្វ៊ីតនៃចំនួនពិត $(u_n)$ កំនត់គ្រប់ $n \in IN$ ដោយ ៖

$u_0 = 0 \,;\, u_1 = 1$ និងទំនាក់ទំនង $u_{n+2} = \sqrt{3}u_{n+1} - 4u_n$

ក.គេតាង $z_n = u_{n+1} - \dfrac{\sqrt{3}-i}{2}.u_n$ គ្រប់ $n \in IN$ ។

ចូរស្រាយថា $z_{n+1} = \dfrac{\sqrt{3}+i}{2}.z_n$ រួចគណនា $u_n$ ជាអនុគមន៍នៃ $n$ ។

ខ.ទាញរកតួទូទៅនៃស្វ៊ីត $(u_n)$ ។

